**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

## លក្ខខណ្ឌគតិយុត្តនៃប្រកាសនីយបត្រតក្កកម្ម និងនីតិវិធី នៃការចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **យាន ជាមីង**
លោក **ហេង សំណាង**

ណែនាំស្រាវជ្រាវដោយ
លោក **យឹម ឧត្តម**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទទាំងពីររូបឈ្មោះ **យាន ដាម៉ីខ** និង **ហេខ សំណាខ** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការថ្លែងអំណរគុណ និងសូមសម្តែងនូវភាពកតញ្ញូកតវេទីជូនចំពោះលោកអ្នកមានគុណ៖

១. លោកឪពុក **យាន ម៉ុនធឿន** និង អ្នកម្តាយ **សំ សេខអាន**

២. លោកឪពុក **ហេខ យាខ** និង អ្នកម្តាយ **ផាន់ ដាលី**

សូមលំឱនកាយ សម្តែងនូវកិច្ចកតញ្ញូធម៌យ៉ាងជ្រាលជ្រៅជាទីបំផុតដែលលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនៗ ប្រកបដោយព្រហ្មវិហារធម៌ជាពិសេសរាល់ទំនុកបម្រុង គ្រប់បែបយ៉ាង ទាំងផ្នែកសម្ភារៈ ស្មារតី កម្លាំងចិត្ត ថវិកា និងដំបូន្មានល្អៗ តាំងពីកុមារភាព រហូតមកដល់បច្ចុប្បន្ននេះ ព្រមទាំងផ្តល់ឱកាសអោយរូបខ្ញុំទាំងពីររូប ទទួលបាននូវចំណេះដឹងដែលជាទានបំភ្លឺផ្លូវ និងជាទ្រព្យធនដែលមិនចេះបាត់បង់ និងមិនអាចកាត់ថ្លៃបាន របស់លោកអ្នកមានគុណទាំងទ្វេ។

ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោក លោកស្រីព្រឹទ្ធបុរសរង ព្រមទាំងលោកលោកស្រី សាស្ត្រាចារ្យ និងបុគ្គលិកសិក្សាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ព្រមទាំងការខិតខំបង្ហាត់បង្រៀនអស់ពីកម្លាំងកាយចិត្ត និងបានផ្តល់នូវចំណេះដឹង បទពិសោធន៍ដែលលោកមាន ដើម្បីឱ្យយើងខ្ញុំទទួលបានចំណេះដឹង និងបទពិសោធន៍ជាច្រើន រហូតឈានទៅបញ្ចប់ការសិក្សា ប្រកបដោយភាពជោគជ័យ។

ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ លោក **ឃឹម ឧត្តម** ជាគ្រូដឹកនាំដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃ ហើយបានលះបង់អស់ពីកម្លាំងកាយ និងកម្លាំងចិត្តមិនខ្លាចនឿយហត់ ដើម្បីជួយដឹកនាំ និងជំរុញក្នុងការសរសេរជាស្នាដៃ នេះតាំងពីចាប់ផ្តើមរហូតដល់ការបញ្ចប់ ជាស្ពាពរដែលនេះជាគុណដ៏វិសេសវិសាល ដែលយើងខ្ញុំមិនអាចបំភ្លេចបាន។

ជាចុងក្រោយយើងខ្ញុំ សូមបួងសួងអស់បារមីនៃវត្ថុសក្តិសិទ្ធិទាំងពួង សូមប្រសិទ្ធិពរជ័យសិរីមង្គលវិបុលសុខគ្រប់ប្រការជូនដល់អស់លោកអ្នកមានគុណទាំងឡាយ និងសូមជួយបីបាច់ថែរក្សាលោកអ្នកមានគុណឱ្យមានសុខភាពល្អ ព្រមទាំងសូមជូនពរឱ្យលោកជួបប្រទះនូវពុទ្ធទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២៣ ដែលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចាប់តាំងពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៣ បន្ទាប់ពីបានសិក្សាអស់រយៈពេល៤ឆ្នាំ កន្លងមកនេះយើងបានទទួលនូវចំណេះដឹងជាច្រើនពី លោកគ្រូ អ្នកគ្រូ ក៏ដូចជា សាស្ត្រាចារ្យទាំងឡាយដែលបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ ទោះបីជាព្រះរាជាណាចក្រកម្ពុជាបានជួបវិបត្តិនៃជំងឺកូវីដ១៩ អស់រយៈពេល៣ឆ្នាំក៏ដោយ។ ហេតុដូច្នេះហើយ ដើម្បីធ្វើការវាយតម្លៃ និងវាស់ស្ទង់ទៅលើចំណេះដឹងរបស់យើងខ្ញុំ ដែលបានសិក្សាកន្លងមកក្នុងរយៈពេល៤ឆ្នាំមកនេះ យើងខ្ញុំបានលើកយកនូវប្រធានបទមួយដែលមានចំណងជើងថា "**លក្ខខណ្ឌគតិយុត្តនៃប្រកាសនីយបត្រតក្កកម្ម និងនីតិវិធីនៃការចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិ**" មកធ្វើការសិក្សាស្រាវជ្រាវដើម្បីសរសេរជាសារណាក្នុងការបញ្ចប់ការសិក្សាមួយនេះ ។

មូលហេតុដែលយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទនេះ ព្រោះចង់ស្វែងយល់អំពីមូលហេតុនៃការបង្កើតក៏ដូចជាគោលបំណងរបស់ប្រកាសនីយបត្រតក្កកម្ម។ ក្នុងនោះផងដែរ គឺដើម្បីអោយដឹងបន្ថែមអំពីលក្ខខណ្ឌនៃការផ្តល់ប្រកាសនីយបត្រតក្កកម្ម ព្រមទាំងនីតិវិធីនៃការចុះបញ្ជី និងសិទ្ធិទទួលបានពីការប្រកាសនីយបត្រតក្កកម្មផងដែរ។ ជាពិសេស គឺទទួលបានការយល់ដឹងយ៉ាងច្បាស់ពីភាពដូចគ្នា និងភាពខុសគ្នារវាងការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិផងដែរ។

តាមរយៈស្នាដៃនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អត្ថបទសារណាមួយនេះនឹងចូលរួមជាពិសេសក្នុងការផ្សព្វផ្សាយ និងជាជំនួយដល់ស្មារតីរបស់និស្សិត និងសម្រាប់អ្នកសិក្សាទូទៅ ជាពិសេសសម្រាប់សាមញ្ញជនដែលមានគោលបំណងចង់ស្វែងយល់ និងចង់សិក្សាស្រាវជ្រាវទាក់ទងទៅ នឹងលក្ខខណ្ឌគតិយុត្តនៃប្រកាសនីយបត្រតក្កកម្ម និងនីតិវិធីនៃការចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិផងដែរ។

ដោយសារតែពេលវេលាក្នុងការសិក្សាស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សាមានរយៈពេលខ្លី ហើយម្យ៉ាងវិញទៀត ដោយសារតែចំណេះដឹងយើងខ្ញុំនូវមានកម្រិត យើងខ្ញុំជឿជាក់ថានឹងមានកំហុសដែលអាចកើតមានឡើងដោយអចេតនាមួយចំនួនផងដែរ ទាក់ទងទៅនិង កំហុសអក្ខរាវិរុទ្ធ ខ្លឹមសារអត្ថន័យ និងភាពខ្វះចន្លោះតាមខ្លឹមសារច្បាប់ជាក់ជាពុំខាន។ យើងខ្ញុំរីករាយទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីកែលំអនូវកំហុសឆ្គងពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ក៏ដូចជាមិត្តនិស្សិតទាំងឡាយដើម្បីបំពេញនូវរាល់កំហុសឆ្គង និងចំណុចខ្វះខាតដោយក្តីសោមនស្សរីករាយ។

# មាតិកា

**សេចក្តីផ្តើម** .......... 1

**ជំពូកទី១ ៖ លក្ខខណ្ឌគតិយុត្តនៃប្រកាសនីយបត្រតក្កកម្ម** .......... 4

ផ្នែកទី១ ៖ សញ្ញាណទូទៅនៃប្រកាសនីយបត្រតក្កកម្ម .......... 4

១.១. អ្វីទៅជាប្រកាសនីយបត្រតក្កកម្ម? .......... 4

១.២. អត្ថប្រយោជន៍នៃប្រកាសនីយបត្រតក្កកម្ម .......... 7

ផ្នែកទី២ ៖ តក្កកម្មដែលអាច និងមិនអាចទទួលបានការការពារ .......... 12

២.១. លក្ខខណ្ឌដែលតក្កកម្មអាចទទួលបានប្រកាសនីយបត្រតក្កកម្ម .......... 12

២.២. តក្កកម្មដែលត្រូវបានផាត់ចេញដោយច្បាប់ និងមិនទទួលបានការការពារ .......... 13

**ជំពូកទី២ ៖ នីតិវិធីនៃការចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិ** .......... 15

ផ្នែកទី១ ៖ នីតិវិធីនៃការចុះបញ្ជីតក្កកម្មជាតិ .......... 15

១.១. លក្ខខណ្ឌនៃការចុះបញ្ជី .......... 15

១.២. ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងការការពារ .......... 26

១.៣. មោឃភាពនៃប្រកាសនីយបត្រតក្កកម្ម .......... 28

ផ្នែកទី២ ៖ នីតិវិធីនៃការចុះបញ្ជីតក្កកម្មអន្តរជាតិ .......... 29

២.១. បែបបទនៃការចុះបញ្ជីតក្កកម្មអន្តរជាតិ .......... 29

២.២. សិទ្ធិ និងកិច្ចការពារទទួលបានពីការចុះបញ្ជីជាអន្តរជាតិ .......... 37

**សេចក្តីសន្និដ្ឋាន** .......... 39

**អនុសាសន៍** .......... 41

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

សព្វថ្ងៃ នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងឃើញថា កំពុងយកចិត្តទុកដាក់ទៅលើគ្រប់វិស័យដូចជា សុខាភិបាល កីឡា ការអប់រំ ជាសិសេសវិស័យកម្មសិទ្ធិបញ្ញាតែម្តង។ គេឃើញថាប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជាមានការយកចិត្តទុកក្នុងការវិស័យកម្មសិទ្ធិបញ្ញា ដែលទាក់ទងការច្នៃប្រឌិត ក៏ដូចជាបង្កើតអ្វីដែលថ្មី តាមរយៈការខិតខំបង្កើតអោយចេញជារូបរាងដោយប្រើប្រាស់គំនិតបញ្ញារបស់ពួកគាត់។

ប្រកាសនីយបត្រតក្កកម្ម បានវិវឌ្ឍន៍ជាច្រើនសតវត្សមកហើយ ចាប់តាំងពីឆ្នាំ១៧០០ មកម្ល៉េះ[1] ហើយប្រកាសនីយបត្រតក្កកម្ម ជាផ្នែកមួយដល់ចំណាស់ជាងគេនៅក្នុងកម្មសិទ្ធបញ្ញា ដោយប្រព័ន្ធនេះមានដំណើរការជាច្រើនឆ្នាំមកម្ល៉េះ ហើយឥឡូវនេះយើងមានប្រព័ន្ធទំនើបមួយ។ សព្វថ្ងៃយើងកំពុងតែអភិវឌ្ឍន៍ប្រព័ន្ធអន្តរជាតិដើម្បីធ្វើឱ្យវាកាន់តែទំនើបទៅតាមប្រព័ន្ធនៃការផ្លាស់ប្តូរបច្ចេកវិទ្យា និងផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចផងដែរ។

ប្រកាសនីយបត្រតក្កកម្ម អាចត្រូវបានចាត់ទុកដូចជាមធ្យោបាយរបស់រដ្ឋ ក្នុងការគ្រប់គ្រងលើរាល់ស្នាដៃជា"**តក្កកម្ម**"។ ម៉្យាងទៀត ដើម្បីជាការជាការទាក់ទាញដល់ម្ចាស់តក្កកម្មទាំងឡាយ ឱ្យតក្កកម្មដែលពួកគេខិតខំបង្កើតឡើងដោយលំបាក មកធ្វើការចុះបញ្ជីសុំប្រកាសនីយបត្រនេះ (ក៏ដូចជាចូលខ្លួនមកឲ្យរដ្ឋគ្រប់គ្រងនេះ) រដ្ឋក៏តែត្រូវបង្ហាញ ឬទទួលស្គាល់នូវអត្ថប្រយោជន៍ជាច្រើនដល់ពួកគេផងដែរ។[2] ប្រកាសនីយបត្រតក្កកម្មនេះផងដែរ មានឧបករណ៍គតិយុត្តអន្តរជាតិសំខាន់ពីរដែលគ្រប់គ្រងនៅក្នុងវិស័យនេះ រួមមានអនុសញ្ញាទីក្រុងប៉ារីស **"Paris"** ឆ្នាំ១៨៨៣ និងកិច្ចព្រមព្រៀង **"TRIPS"** ឆ្នាំ១៩៩៤។ អត្ថបទគតិយុត្តអន្តរជាតិទាំងពីរនេះ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធណាស់។ អនុសញ្ញាទីក្រុងប៉ារីស (Paris) ជាប្រភពនៃ នីតិអន្តរជាតិទីមួយដែលគ្រប់គ្រងវិស័យនេះ ហើយកិច្ចព្រមព្រៀង **"TRIPS"** ( Trade-Related Aspects of Intellectual Property Rights) ដែលត្រូវបានបង្កើតឡើងក្នុងក្របខណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក ហៅកាត់ថា **"WTO"** (World Intellectual Property Organization) ដើម្បីពង្រឹងវិស័យពាណិជ្ជកម្មអន្តរជាតិ ក៏ប្រកាសយោងស្ទើរតែទាំងស្រុងទៅរកអនុសញ្ញាទីក្រុងប៉ារីសនេះផងដែរ។[3]

ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ទើបតែបានចាប់កំណើតនាពេលថ្មីៗប៉ុណ្ណោះ តាមរយៈការអនុម័តច្បាប់ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ដែលជាផ្នែកមួយរបស់ប្រទេសកម្ពុជាក្នុងការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ហើយផ្តល់នូវសិទ្ធិផ្តាច់មុខជូនដល់តក្កករក្នុងការបញ្ចេញនូវតក្កកម្មថ្មីៗដល់សាធារណៈជន។ ទាក់ទងទៅនិងការការពារនេះផងដែរ គឺផ្តល់

[1] លោក លឹម យូសូ, "នីតិកម្មសិទ្ធិបញ្ញា", IP lesson(2)_2.pdf។

[2] លោក កាន់ សុទ្ធប៉ូលីន,"នីតិកម្មសិទ្ធិបញ្ញា"។

[3] លោក កាន់ សុទ្ធប៉ូលីន,"នីតិកម្មសិទ្ធិបញ្ញា"។

តាមរយៈការទទួលបាននូវប្រកាសនីយបត្រតក្កកម្ម គឺមានកំណត់ពេលវេលាច្បាស់លាស់ ហើយដែលជាទូទៅប្រទេសជាច្រើនបានកំណត់រយៈពេលនៃការការពារគឺ ២០ឆ្នាំ។ តាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាយើងបានកំណត់ពេលវេលាដូចគ្នានេះផងដែរ។[4] យោងតាមមាត្រា១ ច្បាប់នេះមានគោលដៅ "ការពារតក្កកម្មដែលទទួលបានប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ដែលបានទទួលវិញ្ញាបនបត្រ និងការពារគំនូរឧស្សាហកម្មដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម"។[5]

យោងតាមមាត្រា៣ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម បានចែងអំពីនិយមន័យនៃប្រកាសនីយបត្រតក្កកម្មសំដៅដល់វិញ្ញាបនបត្រគតិយុត្តដែលផ្តល់ឱ្យដោយអាជ្ញាធរសាធារណៈ ឬរដ្ឋឱ្យដល់តក្កករ ដើម្បីការពារតក្កកម្មណាមួយ។[6] "**តក្កកម្ម**" គឺសំដៅទៅលើស្នាដៃ ដែលកើតចេញពីការបង្កើតថ្មី រីឯ "**តក្កករ**" គឺពិតជាជនដែលបានបង្កើតស្នាដៃជាតក្កកម្មមួយឡើង តាមរយៈគំនិតប្រាជ្ញាផ្ទាល់របស់ខ្លួន។ ទាក់ទងទៅនឹងងគោលបំណងនៃការបង្កើតប្រកាសនីយបត្រតក្កកម្មគឺ ជាការការពារដល់ការបង្កើតបច្ចេកទេសទំនើប ដោយវាបានផ្តល់ការលើកទឹកចិត្តទៅលើការបង្ហាញតក្កកម្មព្រមទាំងការអភិវឌ្ឍន៍បន្ថែមទៀត ឬការបង្កើតបច្ចេកវិទ្យាថ្មី។ គោលបំណងនៃប្រកាសនីយបត្រតក្កកម្មមិនត្រឹមតែលើកចិត្តក្នុងការបង្កើតតក្កកម្មថ្មីប៉ុណ្ណោះទេ ថែមទាំងការអភិវឌ្ឍន៍តក្កកម្មដែលជាចំណុចបច្ចេកទេស និងទីផ្សារប្រភេទនេះជំរុញបន្ថែមលើសកម្មភាពក្នុងការលើកទឹកចិត្តដល់ក្រុមហ៊ុនដើម្បីអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីដល់ទីផ្សារ និងមានប្រយោជន៍ដល់សាធារណៈផងដែរ។

ប្រកាសនីយបត្រតក្កកម្ម ជាសិទ្ធដែលទទួលបានការធានាដោយរដ្ឋដល់តក្កករដើម្បីការពារ កុំអោយជនណាម្នាក់ធ្វើការទាញយកប្រយោជន៍ ពីស្នាដៃរបស់ខ្លួនបានដោយ មិនមានអនុញ្ញាតក្នុងរយៈពេលកំណត់មួយជាក់លាក់។ ក្នុងនោះផងដែរ ព្រះរាជាណាចក្រកម្ពុជាបានក្លាយជាសមាជិក នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) តាមរយៈលិខិតតូបករណ៍នៃ ការចូលជាសមាជិកនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០១៦ និងបានដាក់តម្កល់នៅអង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅថ្ងៃ៨ ខែកញ្ញា ឆ្នាំ២០១៦ ដែលបានចូលជាធរមាននៅថ្ងៃ៨ ខែធ្នូ ឆ្នាំ២០១៦។[7]

---

[4] បណ្ឌិត "ឃឹម គីរី", "នីតិកម្មសិទ្ធបញ្ញា", រក្សាសិទ្ធិ ឆ្នាំ២០១៩, កែសម្រួល ឆ្នាំ២០២២។

[5] មាត្រា១ កថាខណ្ឌ១ នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[6] មាត្រា៣ កថាខណ្ឌ១ នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[7] Abacus IP, CAMBODIA, https://vannarachincom.files.wordpress.com/2015/11/e19e98e19e82e19f92e19e82e19e91e19f81e19e9fe19e80e19f8de19ea2e19f86e19e96e19eb8e19e85e19f92e19e94e19eb6e19e94e19f8be19e94e19f92e19e9a.pdf

តាមការសិក្សាអំពីមុខវិជ្ជាកម្មសិទ្ធបញ្ញា ទាក់ទងទៅនឹងប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ យើងសង្កេតឃើញថា ប្រទេសកម្ពុជាបានទទួលផលចំណេញច្រើនគួរសមពីប្រកាសនីយបត្រតក្កកម្មនេះ ទើបយើងខ្ញុំសម្រេចយកប្រធានបទដែលមានចំណងជើងថា "លក្ខខណ្ឌគតិយុត្តនៃប្រកាសនីយបត្រតក្កកម្ម និងនីតិវិធីនៃការចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិ" មកសរសេរជាសារណាផងដែរ។ ការសិក្សាស្រាវជ្រាវមួយនេះ បានជួយអោយយល់កាន់តែច្បាស់ទាំងផ្នែកចំណេះដឹង ក៏ដូចជាទ្រឹស្តីផងដែរ ដែលពាក់ព័ន្ធទៅលើលក្ខខណ្ឌគតិយុត្តនៃប្រកាសនីយបត្រតកម្ម និងនីតិវិធីនៃការចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិ។ ក្នុងន័យនេះ គឺសំដៅទៅលើការលើកទឹកចិត្តទៅកាន់រាល់តក្កករ ដែលបានខំចំណាយពេលវេលាដ៏មានតម្លៃ ព្រមទាំងកំលាំងកាយ កំលាំងចិត្ត និងស្មារតី ដើម្បីបង្កើតអ្វីដែលថ្មី នឹងពុំធ្លាប់មានពីមុនមក ក្នុងការជួយលើកស្ទួយ និងភាពរីកចម្រើនក្នុងវិស័យកម្មសិទ្ធិបញ្ញាអោយកាន់តែប្រសើរឡើង។ ជាងនេះទៅទៀត ការសិក្សា និងស្រាវជ្រាវប្រធានបទនេះ បានផ្តល់នូវតម្លៃអប់រំសំខាន់ទៅកាន់សង្គមជាតិ ព្រមទាំងធ្វើអោយវិស័យកម្មសិទ្ធបញ្ញាមានភាពទូលំទូលាយ ដើម្បីអោយប្រជាពលរដ្ឋទាំងនៅក្នុងស្រុក និងក្រៅស្រុកបានយល់អោយកាន់តែច្បាស់ផងដែរ។ ជាពិសេស ការស្រាវជ្រាវមួយនេះគឺ ទុកសម្រាប់ជាឯកសារ ដ៏មានសារៈសំខាន់សម្រាប់ដល់និស្សិតជំនាន់ក្រោយក្នុងការសិក្សានឹងស្រាវជ្រាវបន្ថែមទៀតផងដែរ។

**តើនីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិមានដំណើរការយ៉ាងដូចម្តេច ?**

ដូចនេះដើម្បីបកស្រាយនូវប្រធានបទខាងលើអោយអស់សេចក្តី និងគ្របដណ្តប់នូវផ្នែកមួយចំនួនធំនៃរបាយការណ៍សារណាបញ្ចប់ការសិក្សានេះ បានបែងចែកជា ២ជំពូកធំៗគឺ **ជំពូកទី១ លក្ខខណ្ឌគតិយុត្តនៃប្រកាសនីយបត្រតក្កកម្ម** ដោយនៅក្នុងនោះរៀបរាប់ពាក់ព័ន្ធទៅនឹងនិយមន័យ បុព្វហេតុ កម្មវត្ថុ និងគោលបំណងនៃប្រកាសនីយបត្រតក្កកម្ម ព្រមទាំងអត្ថប្រយោជន៍ និងលក្ខខណ្ឌគតិយុត្តនៃប្រកាសនីយបត្រតក្កកម្ម និង**ជំពូកទី២ នីតិវិធីនៃការចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិ** រៀបរាប់អំពីការចុះបញ្ជីតក្កកម្មជាតិ និងការចុះបញ្ជីតក្កកម្មអន្តរជាតិ មោឃភាពនៃប្រកាសនីយបត្រតក្កកម្ម ព្រមទាំងសិទ្ធិ និងកិច្ចការពារទទួលបានពីការចុះបញ្ជីជាអន្តរជាតិ។

# ជំពូកទី១

# លក្ខខណ្ឌគតិយុត្តនៃការប្រកាសនីយបត្រ

# ឥក្កកម្ម

# ជំពូកទី១ ៖ លក្ខខណ្ឌគតិយុត្តនៃការប្រកាសនីយបត្រតក្កកម្ម

## ផ្នែកទី១ ៖ សញ្ញាណទូទៅនៃប្រកាសនីយបត្រតក្កកម្ម

### ១.១. អ្វីទៅជាប្រកាសនីយបត្រតក្កកម្ម?

#### ១.១.១. និយមន័យ

ប្រកាសនីយបត្រតក្កកម្ម គឺជាវិញ្ញាបនបត្រដែលបានផ្តល់ដើម្បីការពារតក្កកម្ម[8] ដែលបានចេញដោយការិយាល័យរបស់រដ្ឋាភិបាលណាមួយ ឬការិយាល័យសម្រាប់តំបន់ណាមួយដែលបានដើរតួនាទីក្នុងនាមរដ្ឋច្រើនហើយវាអាស្រ័យទៅតាមរយៈការដាក់ពាក្យសុំ។ រាជរដ្ឋាភិបាលជាអ្នកផ្តល់សិទ្ធិ មួយដល់អ្នកកាន់កាប់ប្រកាសនីយបត្រតក្កកម្មនោះ ដើម្បីរារាំងកុំឱ្យអ្នកដទៃប្រើប្រាស់ ឬលក់ផលិតផលដែលបានទទួលប្រកាសនីយបត្រតក្កកម្មនោះនៅក្នុងដែនដីមួយជាក់លាក់ក្នុងរយៈពេលកំណត់ណាមួយ។ ការផ្តល់សិទ្ធិនេះដើម្បីជម្រុញលើកទឹកចិត្តឱ្យមានគំនិតច្នៃប្រឌិតក្នុងការដោះស្រាយបច្ចេកវិទ្យា។[9] "តក្កកម្ម" គឺសំដៅលើគំនិតរបស់តក្កករ ដែលអាចយកទៅអនុវត្តបាន ក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិទ្យា។[10] មួយវិញទៀត តក្កកម្ម គឺជាផលិតផល ដែលកើតចេញពីគំនិតបញ្ញាផ្ទាល់ របស់តក្កករ ហើយអាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម។ តាមន័យគតិយុត្ត ក៏ដូចជាក្នុងករណីនៃស្នាដៃនិពន្ធដែរតក្កកម្ម គឺត្រូវតែជាផលិតផល នៃគំនិតប្រាជ្ញាផ្ទាល់របស់ តក្កករ ដែលជាអ្នកបង្កើតវា។ រីឯពាក្យថា "តក្កករ"សំដៅលើអ្នកដែលបានបង្កើតស្នាដៃ អ្នកដែលរកឃើញផលិតផលថ្មី ឬដំណើរការផលិតកម្ម ឬអាចជាការរកឃើញអ្វីមួយ ដែលទាក់ទងទៅនឹងផលិតផល ឬដំណើការផលិតកម្ម ។[11] មួយវិញទៀត តក្កករ សំដៅលើសិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម គឺជាកម្មសិទ្ធិរបស់តក្កករ ដែលជាអ្នកបង្កើតស្នាដៃ និងយកទៅចុះបញ្ជីបានមុនទេ។ តក្កករជាបុគ្គលដែលផលិតស្នាដៃ ដូចជានិយោជិតរបស់សហគ្រាស កម្មសិក្សាការី ឬអាចជាមន្ត្រីនៅក្នុងជំនាញផលិតកម្ម នៃស្ថាប័នរដ្ឋ។

យោងតាមអង្គការកម្មសិទ្ធិបញ្ញាពិភពលោក "**WIPO**" **(World Intellectual Property Organization)** ក៏បានកំណត់និយមន័យឱ្យប្រកាសនីយបត្រតក្កកម្មផងដែរ ដោយសំដៅទៅសិទ្ធិផ្តាច់មុខ ផ្តល់ឱ្យចំពោះតក្កកម្មមួយ ដែលអាចជាផលិតផលមួយ ឬជាដំណើរការផលិតកម្មណាមួយដែលរួមចំណែកដល់មធ្យោបាយថ្មី និងការ

---

[8] តើអ្វីទៅជាប្រកាសនីយបត្រតក្កកម្ម, "នាយកដ្ឋានកម្មសិទ្ធបញ្ញា",
 Department of Intellectual Property Rights (cambodiaip.gov.kh)

[9] បណ្ឌិត "ទេព សុខ", "នីតិកម្មសិទ្ធបញ្ញា"។

[10] មាត្រា៣ កថាខណ្ឌ១ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[11] មាត្រា៣ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

បង្កើតអ្វីមួយ ឬរួមចំណែកដល់ដំណោះស្រាយបច្ចេកទេសថ្មីណាមួយតបទៅនឹងចំណោទបញ្ហាណាមួយផងដែរ។[12]

### ១.១.២. បុព្វហេតុ កម្មវត្ថុ និងគោលបំណងនៃការបង្កើត

➢ **បុព្វហេតុនៃការកកើត**

ប្រកាសនីយបត្រតក្កកម្ម បានវិវឌ្ឍន៍ជាច្រើនឆ្នាំមកហើយ គឺមានចាប់តាំងពីឆ្នាំ១៧០០មកម្ល៉េះ[13] ប្រព័ន្ធនេះមានដំណើរការជាច្រើនឆ្នាំមកហើយ ហើយឥឡូវនេះយើងមានប្រព័ន្ធទំនើបមួយផងដែរ។ យើងកំពុងតែអភិវឌ្ឍប្រព័ន្ធអន្តរជាតិ ដើម្បីធ្វើឱ្យវាកាន់តែទំនើបទៅតាមប្រព័ន្ធនៃការផ្លាស់ប្តូរបច្ចេកវិទ្យា និងផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ច។ ក្នុងនោះផងដែរប្រទេសកម្ពុជាក៏បានចូលជាសមាជិក នៃអង្គការពាណិជ្ជកម្មពិភពលោកហើយផ្តល់នូវសិទ្ធិផ្តាច់មុខជូនដល់តក្កករ ក្នុងការបញ្ចេញនូវតក្កកម្មថ្មីៗដល់សាធារណជនដែលត្រូវបានទទួលស្គាល់នៅក្នុងឆ្នាំ២០០៣។[14]

➢ **កម្មវត្ថុនៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម**

ដើម្បីទទួលបាននូវប្រកាសនីយបត្រតក្កកម្មមួយ គេត្រូវទៅមើលទៅលើថាតើភាពប៉ិនប្រសប់សមត្ថភាពទេពកោសល្យ ក៏ដូចជាចំណង់ចំណូលចិត្តក្នុងការច្នៃប្រឌិត ការបង្កើត ផលិតនូវអ្វីៗដែលថ្មី ឬស្រាវជ្រាវស្វែងរកនូវរបកគំហើញថ្មីៗ ដែលមានលក្ខណៈពិសេសជាងគេដើម្បីជាស្នាដៃប្រវត្តិសាស្ត្ររបស់មនុស្សម្នាក់ៗបានបំពេញនូវសេចក្តីត្រូវការប្រចាំថ្ងៃរបស់ពួកគេ ក៏ដូចជាដើម្បីជាប្រយោជន៍ដល់មនុស្សជាតិទាំងមូលបានដែរ។ ក្នុងករណីរកឃើញថា មានការលួចចម្លងស្នាដៃដែលមានស្រាប់ ឬធាតុផ្សំដែរបានរកឃើញនោះសុទ្ធតែមាននៅក្នុងធម្មជាតិស្រាប់នោះ តក្កកម្មដែលបានរកឃើញនោះនឹងមិនអាចត្រូវបានផ្តល់ប្រកាសនីយបត្រតក្កកម្មឡើយ។

➢ **គោលបំណងនៃប្រកាសនីយបត្រតក្កកម្ម**

គោលបំណងនៃប្រកាសនីយបត្រតក្កកម្មគឺការពារ និងលើកទឹកចិត្តទៅលើការបង្ហាញរាល់តក្កកម្ម ដែលតក្កករបានបង្កើត ដែលទាក់ទងទៅនឹងបច្ចេកវិទ្យាថ្មីទំនើប ព្រមទាំងការអភិវឌ្ឍនូវអ្វីដែលថ្មីបន្ថែមទៀត។ ជាសរុបមកតាមរយៈប្រកាសនីយបត្រតក្កកម្មអាចធ្វើអោយមានការផ្លាស់ប្តូរបច្ចេកវិទ្យាល្អៗ ដើម្បីភាពរីកចម្រើនផងដែរ។[15]

---

[12] លោក "កាន់ សុទ្ធប៉ូលីន", "នីតិកម្មសិទ្ធបញ្ញា"។

[13] លោក លឹម យូសូ, "នីតិកម្មសិទ្ធិបញ្ញា", IP lesson(2)_2.pdf

[14] Abacau IP Cambodia, "ប្រកាសនីយបត្រតក្កកម្ម", https://vannarachincom.files.wordpress.com/2015/11/e19e98e19e82e19f92e19e82e19e91e19f81e19e9fe19e80e19f8de19ea2e19f86e19e96e19eb8e19e85e19f92e19e94e19eb6e19e94e19f8be19e94e19f92e19e9a.pdf

[15] លោក លឹម យូសូ "នីតិកម្មសិទ្ធបញ្ញា"។

យោងតាមមាត្រា២ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម បានចែងអំពីគោលបំណងនៃប្រកាសនីយបត្រតក្កកម្ម ក្នុងនោះបានចែងថា៖

- លើកទឹកចិត្តចំពោះការច្នៃប្រឌិតថ្មី និងចំពោះការស្រាវជ្រាវ និងការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។
- ជំរុញ និងលើកទឹកចិត្តការធ្វើពាណិជ្ជកម្ម ក្នុងនិងក្រៅប្រទេស និងការវិនិយោគ។
- លើកទឹកចិត្តចំពោះការផ្ទេរបច្ចេកវិទ្យាមកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយសម្រួលសកម្មភាពឧស្សាហកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ច។
- ផ្តល់ការការពារចំពោះសិទ្ធិនៃកម្មសិទ្ធិឧស្សាហកម្ម និងប្រឆាំងចំពោះការរំលោភសិទ្ធិខាងលើ ក៏ដូចជាប្រឆាំងនឹងការធ្វើជំនួញមិនស្របច្បាប់ ។

### ១.១.៣. ប្រភេទនៃប្រកាសនីយបត្រតក្កកម្ម

តាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាការស្នើសុំប្រកាសនីយបត្រតក្កកម្មត្រូវបានចែកជា ពីរផ្នែក គឺការស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិ និងប្រកាសនីយបត្រតក្កកម្មបរទេស។

➢ **ប្រកាសនីយបត្រតក្កកម្មជាតិ៖**

រាល់ការរកឃើញនូវស្នាដៃថ្មីទាំងឡាយណាដែលបានរកឃើញហើយស្ថិតនៅក្នុងប្រទេសដែលបានស្នើសុំប្រកាសនីយបត្រតក្កកម្ម ហើយសំណុំនៃលិខិតស្នើសុំនេះត្រូវបានគេហៅថាជា សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិហើយទាក់ទងទៅនិងបែបបទក្នុងការស្នើសុំចុះបញ្ជីត្រូវតែអនុលោមតាមច្បាប់ជាអ្នកកំណត់។ ជាទូទៅគ្រប់ការរកឃើញនូវអ្វីដែលថ្មីគេហៅថា "តក្កកម្ម" ដាច់ខាតត្រូវតែស្នើសុំអោយមានការការពារ រីឯទាក់ទងទៅនឹងបែបបទស្នើសុំដែលម្ចាស់តក្កកម្មចាំបាច់ត្រូវតែបំពេញរួមមាន ពាក្យសុំ សេចក្តីអធិប្បាយ សេចក្តីអះអាង និងខ្លឹមសារសង្ខេបជាដើម។[16]

➢ **ប្រកាសនីយបត្រតក្កកម្មបរទេស៖**

ប្រកាសនីយបត្រតក្កកម្មបរទេស គឺសំដៅទៅរាល់តក្កកម្មដែលបានរកឃើញមិនស្ថិតនៅក្នុងប្រទេសដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម មានន័យថា ប្រកាសនីយបត្រតក្កកម្មដែលបានទទួលនៅក្នុងប្រទេសណាមួយ ពុំមែនមានន័យថាតក្កកម្មនោះសុទ្ធសឹងតែទទួលបានការការពារទូទាំងពិភពលោកទាំងមូលនោះទេផ្ទុយទៅវិញវាមានអានុភាពត្រឹមតែដែនដីដែលបានធ្វើការចុះបញ្ជីតែប៉ុណ្ណោះ។ ក្នុងករណីដែលគេចង់ការពាររាល់តក្កកម្មនៅកន្លែងណាមួយនោះ គេត្រូវស្នើសុំចុះបញ្ជីនៅកន្លែងនោះផ្ទាល់ផងដែរ។ ទាក់ទងទៅនឹងអ្នកដាក់ពាក្យស្នើសុំ ត្រូវផ្តល់ជូនដល់មន្ត្រីកាន់កាប់បញ្ជីនូវកាលបរិច្ឆេទ និងលេខនៃសំណុំលិខិតស្នើសុំទាំងឡាយដែលខ្លួនបាន

[16] បណ្ឌិត "ឃឹម គីរី", "នីតិកម្មសិទ្ធបញ្ញា", រក្សាសិទ្ធិ ឆ្នាំ២០១៩, កែសម្រួល ឆ្នាំ២០២២។

ដាក់នៅឯបរទេស ហើយដែលវាបានពាក់ព័ន្ធទៅនឹងតក្កកម្មដូចគ្នា ឬស្ទើរតែដូចគ្នា ដូចដែលបានធ្វើការអះអាងនៅក្នុងសំណុំនៃលិខិតស្នើសុំ។[17]

**ឧទាហរណ៍៖** ប្រសិនបើលោក ហា សាគី បានរកឃើញរថយន្តដែលបើកបរដោយខ្លួនឯង(Auto Drive) ហើយគាត់បានចុះបញ្ជីនៅ ក្នុងប្រទេសជប៉ុន នោះការការពារមានតែនៅក្នុងប្រទេសជប៉ុនប៉ុណ្ណោះ ប្រសិនបើគាត់ចង់ឱ្យមានការ ការពារនៅកម្ពុជា នោះគាត់ដាច់ខាតត្រូវធ្វើការចុះបញ្ជីនៅកម្ពុជា។ ទោះជាយ៉ាងណា គេក៏អាចទទួលបាននូវការការពារជាអន្តរជាតិផងដែរ ដោយយោងតាមអនុសញ្ញា ឬសន្ធិសញ្ញា ឬក៏កិច្ចព្រមព្រៀងស្តីពីកម្មសិទ្ធិបញ្ញាដែលស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំដោយអង្គការអន្តរជាតិចំនួនពីរ គឺអង្គការ WIPO និងអង្គការ WTO។ ហើយអង្គការដែលគ្រប់គ្រងវិស័យកម្មសិទ្ធិបញ្ញាធំជាងគឺ WIPO។ រដ្ឋ ដែលជាសមាជិករបស់ WIPO និង WTO ត្រូវទទួលស្គាល់នូវការការពារកម្មសិទ្ធិបញ្ញា។ ក្នុងនោះផងដែរ ប្រទេសដែលជាសមាជិកនីមួយៗ បានកំណត់នូវលក្ខខណ្ឌ ដើម្បីផ្តល់នូវការការពារខុសៗគ្នា ហើយម្យ៉ាងទៀតតក្កកម្មនោះមិនមែនជាតក្កកម្ម ថ្មីទៀតទព្រោះថាតក្កកម្មត្រូវបានគេដឹងឮ នៅក្នុងប្រទេសដែលបានចុះបញ្ជីលើកដំបូងរួចមកហើយ។ មូលហេតុនេះហើយ ដែលអ្នកដាក់ពាក្យសុំត្រូវបង្ហាញនូវកាលបរិច្ឆេទអាទិភាព នៃសំណុំលិខិតស្នើសុំ ដែលបានចុះបញ្ជីដំបូងគេដែលខ្លួនបានចុះនៅក្នុងប្រទេសណាមួយ ឬនៅក្នុងតំបន់ណាមួយ។ ចំពោះទម្រង់បែបបទនៃពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មបរទេស គឺវាអាស្រ័យទៅតាមបទដ្ឋានគតិយុត្តនៃបណ្តាប្រទេសដែលអ្នកដាក់ពាក្យសុំបានស្នើនោះ។

### ១.២. អត្ថប្រយោជន៍នៃប្រកាសនីយបត្រតក្កកម្ម

ផលប្រយោជន៍ដែលម្ចាស់ប្រកាសនីយបត្រតក្កកម្មទទួលបាន គឺមានសិទ្ធផ្តាច់មុខទៅលើរង្វង់ដែនដីរបស់ខ្លួនតាមរយៈការប្រើប្រាស់ ការលក់ ឬការនាំចូលនៃតក្កកម្មរបស់ខ្លួន។[18] ម្យ៉ាងវិញទៀត ក្រៅពីទទួលបានសិទ្ធលើរង្វង់ដែនដីរបស់ខ្លួនហើយនោះ ប្រកាសនីយបត្រតក្កកម្មក៏មានអត្ថប្រយោជន៍ផ្សេងទៀតទៅកាន់តក្កករផងដែរ ដូចជាការប្រឆាំងទៅនឹងអំពើនៃការក្លែងបន្លំ ការរំលោភបំពាន ការលួចចម្លងទាំងឡាយណា ដែលប៉ះពាល់ដល់សិទ្ធិលើម្ចាស់ប្រកាសនីយបត្រតក្កកម្មទាំងលើផលិតផល ឬរាល់ដំណើរការនៃផលិតកម្ម ព្រមទាំងលើមធ្យោបាយនានាដែលត្រូវបានប្រើប្រាស់សម្រាប់ជាជំនួយក្នុងដំណើរការផលិត ឬដល់ដំណើរការនៃផលិតកម្មក្រោយពេលចុះបញ្ជីរួចផងដែរ។[19]

---

[17] មាត្រា៣០ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[18] លោក "លឹម យូសូ","នីតិកម្មសិទ្ធបញ្ញា"។

[19] លោក "កាន់ សុទ្ធប៉ូលីន", "នីតិកម្មសិទ្ធបញ្ញា"។

ប្រកាសនីយបត្រតក្កកម្ម ក៏បានជំរុញដល់ការលើកកម្ពស់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់សហគ្រាស ព្រោះតែវិញ្ញាបនបត្រគតិយុត្តប្រភេទនេះ ត្រូវបានចាត់ទុកថាជាធាតុផ្សំមួយនៃទ្រព្យសកម្មរបស់សហគ្រាស និងជាប្រភពនៃការទាក់ទាញរបស់អ្នកបណ្តាក់ទុនដើម្បីបង្កើននូវមូលធនវិនិយោគរបស់សហគ្រាសផងដែរ។[20]

### ១.២.១. សិទ្ធិដែលទទួលបានរបស់តក្កករ

ការសម្រេចផ្តល់ជូនដល់អ្នកដាក់ពាក្យស្នើសុំនូវប្រកាសនីយបត្រតក្កកម្ម មានន័យថា រដ្ឋព្រមទទួលស្គាល់សិទ្ធិមួយចំនួនដែលច្បាប់នេះបានកំណត់អោយដល់អ្នកស្នើសុំ នៅក្នុងឋានៈជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនិយាយមួយបែប និងជាម្ចាស់នៃតក្កកម្មផ្ទាល់និយាយមួយបែបទៀត។ សិទ្ធិនេះអាចបកស្រាយក្នុងន័យពីរយ៉ាង ដោយក្នុងន័យវិជ្ជមាននៃសិទ្ធិ សិទ្ធិនេះ អាចអនុញ្ញាតឱ្យម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម ធ្វើអាជីវកម្មផ្តាច់មុខលើតក្កកម្មនេះតែឯងបាន។ ប៉ុន្តែក្នុងន័យអវិជ្ជមាននៃសិទ្ធិវិញ សិទ្ធិនេះក៏នឹងអនុញ្ញាតឱ្យម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម អាចហាមឃាត់ តតិយជនណាម្នាក់មិនឱ្យធ្វើអាជីវកម្មលើតក្កកម្មរបស់ខ្លួនបានផងដែរ។ តតិយជនណាម្នាក់ដែលហ៊ានធ្វើអាជីវកម្មលើ តក្កកម្មដែលបានចុះបញ្ជីសុំប្រកាសនីយបត្រតក្កម្មដោយគ្មានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម នឹងត្រូវចាត់ទុកថាជាការរំលោភលើ សិទ្ធិស្របច្បាប់របស់ តក្កករនេះ ហើយក្នុងករណីនេះ ក៏នឹងមានយន្តការដោះស្រាយ សំដៅធានាដល់សិទ្ធិស្របច្បាប់នោះ ឱ្យដល់ម្ចាស់សិទ្ធិផងដែរ។

ជាក់ស្តែងក្រោយពីតក្កករបានទទួលនូវប្រកាសនីយបត្រតក្កកម្មហើយនោះ តក្កកម្មដែលតក្កករបានរកឃើញនោះនិងទទួលបាននូវសិទ្ធិលក្ខណៈពិសេស ពីរគឺ (សិទ្ធិសេដ្ឋកិច្ច) និង (សិទ្ធិសីលធម៌)។ សិទ្ធិសេដ្ឋកិច្ច គឺសំដៅម្ចាស់តក្កកម្មមានសិទ្ធិផ្តាច់មុខទៅលើតក្កកម្មរបស់ខ្លួន ដោយធ្វើការលក់ដូរ ឬ បោះពុម្ពផ្សាយដើម្បីទទួលបានថវិកាដើម។ ហើយសិទ្ធសីលធម៌ គឺសំដៅសិទ្ធដែលតក្កករទទួលបាន ក្រោយពីបានខិតខំប្រើប្រាស់គំនិតប្រាជ្ញាផ្ទាល់ ដើម្បីបង្កើតស្នាដៃជាតក្កកម្មមួយ។ ហើយសិទ្ធិសីលធម៌នេះផងដែរ គឺមានជារៀងរហូតដែលគ្មានអាជ្ញាយុកាលនោះទេ ហើយតក្កកម្មនោះគឺមិនអាចធ្វើការផ្ទេរ ឬប្តូរទៅអោយអ្នកដ៏ទៃបានឡើយ គឺមានតែម្ចាស់នៃតក្កកម្មតែមួយគត់ដែលអាចទទួលបាននូវសិទ្ធិសីលធម៌នេះ។[21]

ម្ចាស់តក្កកម្មក៏មានសិទ្ធិក្នុងការធ្វើអាជីវកម្មដោយពុំចាំបាច់មានការអនុញ្ញាត ក្នុងន័យនេះគេអាចធ្វើអាជីវកម្មលើតក្កកម្មនោះបាន ដោយពុំចាំបាច់មានការអនុញ្ញាតពីម្ចាស់សិទ្ធិឡើយ។ ករណីនេះ ទោះបីជាមាន ឬគ្មានការយល់ព្រម ពីម្ចាស់សិទ្ធិក៏ដោយ ក៏ពុំមែនជាបញ្ហាចោទនោះដែរ មិនតែប៉ុណ្ណោះការធ្វើអាជីវកម្មទាំងនោះ

---

[20] WIPO, ˝intellectual Property a power tool for Economic Growth˝, https://www.wipo.int/portal/en/index.html

[21] លោក ˝កាន់ សុទ្ធប៉ូលីន˝,˝នីតិកម្មសិទ្ធបញ្ញា˝។

ត្រូវបានចាត់ទុកថាជាការធ្វើ អាជីវកម្មដោយស្របច្បាប់។ ម្ចាស់តក្កកម្ម អាចធ្វើអាជីវកម្មបានលុះណាតែបានគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

- ជាសេចក្ដីតម្រូវចាំបាច់សម្រាប់ប្រយោជន៍សាធារណៈ ជាពិសេសផ្នែក សន្តិសុខ អាហារូបត្ថម្ភ សុខាភិបាល និងក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ។
- តុលាការមានសមត្ថកិច្ចបានសម្រេចថា របៀបនៃការធ្វើអាជីវកម្មរបស់តក្កករ ការធ្វើអាជីវកម្មដោយជនដែលទទួលបាននូវអាជ្ញាប័ណ្ណនោះ មានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែងដោយស្មោះត្រង់។

ទោះជាយ៉ាងណាក៏ដោយ ក៏ផលប្រយោជន៍របស់តក្កករមិនត្រូវបានបាត់បង់ទេ ប្រសិនបើរដ្ឋធ្វើអាជីវកម្មដោយខ្លួនឯង នោះរដ្ឋត្រូវចេញសំណងជួសជុលការខូចខាតដល់តក្កករ ឬម្ចាស់សិទ្ធិ។ បើអាជីវកម្មធ្វើឡើងដោយតតិយជន នោះតតិយជនគឺជាអ្នក ទទួលខុសត្រូវលើបន្ទុកនៃសំណងដល់ម្ចាស់សិទ្ធិ ទៅតាមតម្លៃសេដ្ឋកិច្ច ហើយជាពិសេសការធ្វើអាជីវកម្មរបស់តតិយជននោះ ត្រូវតែគោរពតាមកម្មវត្ថុដែលបានអនុញ្ញាត។[22]

### **១.២.២. ជំរុញការបង្កើតថ្មី និងអភិវឌ្ឍន៍បច្ចេកវិទ្យា**

គំនិតច្នៃប្រឌិត និងការបង្កើតថ្មី គឺជាបេះដូងនៃអាជីវកម្មប្រកបដោយជោគជ័យជាច្រើន ហើយគំនិតទាំងនោះចាំបាច់ត្រូវធ្វើការអភិវឌ្ឍន៍ ដោយធ្វើការប្រែក្លាយវាទៅជាផលិតផល ឬសេវាប្រកបដោយការច្នៃប្រឌិតថ្មី ហើយធ្វើពាណិជ្ជកម្ម ទំនិញ ឬសេវាទាំងនោះប្រកបដោយជោគជ័យ ដើម្បីធ្វើឱ្យអាជីវកម្មតក្កករ អាចយកបាននូវផលប្រយោជន៍ពីគំនិតច្នៃប្រឌិត និងការបង្កើតថ្មីរបស់តក្កករ។ តក្កករក៏អាចប្រើប្រាស់ប្រកាសនីយបត្រតក្កកម្ម ដើម្បីទទួលបានចំណូល ជាលាភការតាមរយៈការផ្ដល់អាជ្ញាប័ណ្ណប្រកាសនីយបត្រតក្កកម្ម ប្រកបដោយការច្នៃប្រឌិតទៅឱ្យ សហគ្រាស ដែលមានសមត្ថភាពក្នុងការធ្វើពាណិជ្ជកម្ម គំនិតច្នៃប្រឌិតទាំងនេះ។ ទីផ្សារ ផលិតផលទើបណែនាំថ្មីរបស់តក្កករ អាចត្រូវបានការពារប្រកបដោយប្រសិទ្ធភាព តាមរយៈការទទួលបាននូវ ការការពារប្រកាសនីយបត្រតក្កកម្ម ម្ចាស់ប្រកាសនីយបត្រតក្កកម្មមួយរូបអាចបើកផ្លូវផ្សេងទៀត ដូចជាធ្វើអាជ្ញាបណ្ណ ឬការចងសម្ព័ន្ធជាយុទ្ធសាស្ត្រ ជាដើម។ នៅមានអត្ថប្រយោជន៍ ច្រើនផ្សេងទៀត ដែលម្ចាស់តក្កកម្មអាចទទួលបានពីការសុំប្រកាសនីយបត្រតក្កកម្មនេះពីរដ្ឋៈ ប្រកាសនីយបត្រតក្កកម្ម អាចត្រូវបានចាត់ទុកដូចជាការធានាមួយរបស់រដ្ឋ ដើម្បីប្រឆាំងទល់នឹង អំពើនៃការក្លែងបន្លំទាំងឡាយ ចំពោះតក្កកម្មដែលជា កម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មឱ្យដល់តក្កករ។ តាមរយៈវត្តមាននៃប្រកាសនីយបត្រតក្កកម្មអំពើនៃការក្លែងបន្លំតក្កកម្ម នឹងត្រូវផ្ដន្ទាទោសតាមច្បាប់ស្ដីពី "ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានសារៈប្រយោជន៍ និងគំនូសឧស្សាហកម្មនេះជាក់ជាមិនខាន។ ប្រកាសនីយបត្រតក្កកម្មនេះ ជម្រុញការលើកទឹកចិត្តដល់ការលើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច

[22] លោក "ឃឹម ឧត្តម", "តក្កកម្ម និងប្រកាសនីយបត្រតក្កកម្ម"។

របស់សហគ្រាស ពីព្រោះ វិញ្ញាបនបត្រគតិយុត្តិប្រភេទនេះ នឹងត្រូវបានចាត់ទុកថាធាតុផ្សំមួយ នៃទ្រព្យសកម្មរបស់សហគ្រាស ហើយក៏ជាប្រភពនៃការទាក់ទាញអ្នកបណ្តាក់ទុន ដើម្បីបង្កើត នូវមូលនិធិវិនិយោគរបស់សហគ្រាសផងដែរ។

មានមូលហេតុធំៗ បួនយ៉ាងដែលអាចគាំទ្រដល់ សារប្រយោជន៍ខាងសេដ្ឋកិច្ច របស់សហគ្រាស ជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនេះមាន ៖

- ពត៌មានស្តីពី តក្កកម្មដែលបានរៀបរាប់នៅក្នុងប្រកាសនីយបត្រតក្កកម្ម នឹងជួយសម្រួលដល់ការផ្ទេរបច្ចេកវិទ្យា និងដល់ការវិនិយោគរបស់សហគ្រាស។
- ប្រកាសនីយបត្រតក្កកម្ម និងជួយលើកទឹកចិត្តដល់ការស្រាវជ្រាវ និងអភិវឌ្ឍបន្តបន្ទាប់ទៀតរបស់សហគ្រាស។
- ប្រកាសនីយបត្រតក្កកម្ម នឹងជួយពន្លឿនដល់ការបង្កើតបច្ចេកវិទ្យាថ្មីៗក៏ដូចជាដល់ការបង្កើតមុខជំនួញថ្មីៗដល់សហគ្រាស។
- ប្រកាសនីយបត្រតក្កកម្ម គឺជាកូនសោរដ៏សំខាន់បំផុតក្នុងការសហការគ្នាក្នុងវិស័យជំនួញ (ដូចជាការរួមបញ្ចូលបច្ចេកវិទ្យាគ្នា) ដើម្បីអភិវឌ្ឍសហគ្រាសរៀងៗខ្លួន និងអាចជាប្រភពចំណូលបន្ថែមរបស់សហគ្រាសតាមរយៈការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មលើតក្កកម្មនោះ ផងដែរ។

ប្រកាសនីយបត្រតក្កកម្មក៏អាចចាត់ទុកដូចជាយុទ្ធសាស្ត្រ មួយដ៏ល្អប្រសើរបំផុតក្នុងការផ្សព្វផ្សាយកេរ្តិ៍ឈ្មោះ និងដើម្បីពង្រឹងនីត្យានុភាពរបស់សហគ្រាសដែលជាម្ចាស់ប្រកាសនីយបត្រតក្កកម្ម ទៅដល់បណ្តាសាធារណជន ក៏ដូចជាអតិថិជន និងដៃគូប្រកួតប្រជែងរបស់សហគ្រាសនោះផងដែរ។ ស្ថិតក្នុងភាពជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនេះ សហគ្រាសទាំងឡាយរមែងមានឥទ្ធិពលខ្ពស់ជាងគេក្នុងទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងដៃគូនានារបស់ខ្លួនជានិច្ច។[23]

### ១.១.៣. សិទ្ធិផ្តាច់មុខ និងឧត្តមភាពទីផ្សារ

ប្រកាសនីយបត្រតក្កកម្ម អាចបានត្រូវចាត់ទុកថាជាកម្មសិទ្ធិផ្តាច់មុខ ដោយសារតែម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនោះមានការគ្រប់គ្រងពេញលេញ លើការផលិត ការលក់ និងការប្រើប្រាស់គំនិតច្នៃប្រឌិតនោះ ។ ប្រកាសនីយបត្រតក្កកម្មអនុញ្ញាតឱ្យម្ចាស់របស់វា ទាញយកផលប្រយោជន៍ ជាសម្ភារៈ ដែលជារង្វាន់សម្រាប់កិច្ចការ និងការប្រឹងប្រែងខាងបញ្ញាញាណរបស់ខ្លួន។ តក្កកម្មនេះ អាចនឹងត្រូវបានយកទៅធ្វើ

[23] បណ្ឌិត "ទេព សុខ", "នីតិកម្មសិទ្ធបញ្ញា", ឆ្នាំសិក្សា២០២២-២០២៣។

អាជីវកម្មលុះត្រាណាតែមានការអនុញ្ញាតពីម្ចាស់របស់ប្រកាសនីយបត្រតក្កកម្ម ជាមុនសិន។ ហេតុផលសម្រាប់ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មលើតក្កកម្មរបស់លោកអ្នកវានឹងនាំឱ្យតក្កករ មានឋានៈជា ៖

- **សិទ្ធិផ្តាច់មុខ៖** ប្រកាសនីយបត្រតក្កកម្មផ្តល់នូវសិទ្ធិផ្តាច់មុខដែលជាធម្មតាអនុញ្ញាតឱ្យអាជីវកម្មតក្កករប្រើប្រាស់ និងធ្វើអាជីវកម្ម លើតក្កកម្មនោះរយៈពេល ២០ឆ្នាំ គិតចាប់តាំងពីកាលបរិច្ឆេទនៃការដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម។
- **ផ្តល់នូវទីតាំងដ៏រឹងមាំលើទីផ្សារ៖** តាមរយៈសិទ្ធិផ្តាច់មុខទាំងនេះតក្កករ ដែលបានចុះបញ្ជី រួចហើយ អាចកាត់បន្ថយបាននូវការប្រកួតប្រជែង ហើយបង្កើតឡើងនូវទីតាំងរឹងមាំ ប្រកបដោយឧត្តមភាពសម្រាប់ទីផ្សារ ជាអ្នកមានតួនាទីលេចធ្លោមុនគេ។
- **ផ្តល់ផលចំណូលត្រឡប់មកវិញខ្ពស់ចំពោះការវិនិយោគ៖** ដោយបានបោះទុនវិនិយោគជា ប្រាក់ និងពេលវេលាមួយចំនួនធំ ក្នុងការបង្កើតផលិតផល ប្រកបដោយគំនិតច្នៃប្រឌិត អាជីវកម្មរបស់តក្កករអាចធ្វើពាណិជ្ជកម្មលើគំនិតច្នៃប្រឌិតនោះ ក្រោមស្លាកសិទ្ធិផ្តាច់មុខទាំងនេះ ហើយអាចឱ្យអាជីវកម្ម របស់តក្កករ ទទួលបាននូវផលចំណូលខ្ពស់ជាងមុនអំពីការធ្វើវិនិយោគនេះ។
- **ឱកាសក្នុងការផ្តល់អាជ្ញាប័ណ្ណ ឬលក់តក្កកម្ម៖** ប្រសិនបើតក្កករ សម្រេចមិនធ្វើអាជីវកម្មប្រកាសនីយបត្រតក្កកម្មដោយខ្លួនឯងទេ តក្កករអាចលក់ ឬផ្តល់អាជ្ញាប័ណ្ណចំពោះសិទ្ធិ នៃការប្រើប្រាស់វាដើម្បីឱ្យសហគ្រាសដទៃធ្វើពាណិជ្ជកម្មតក្កកម្មនេះ ហើយវាក៏ជាប្រភពមួយ នៃប្រាក់ចំណូលសម្រាប់អាជីវកម្មរបស់តក្កករ ដែរ។
- **បង្កើតថាមពលក្នុងការចរចារ៖** ប្រសិនបើអាជីវកម្មរបស់តក្កករ ស្ថិតក្នុងតំណាក់កាលនៃការទទួលបាននូវសិទ្ធិ ដើម្បីប្រើប្រាស់ប្រកាសនីយបត្រតក្កកម្ម របស់សហគ្រាសដទៃមួយទៀតតាមរយៈកិច្ចសន្យាអាជ្ញាប័ណ្ណនោះរូបភាពនៃការប្រកាសនីយបត្រតក្កកម្មរបស់តក្កករ និងជួយលើកម្ពស់ថាមពលសម្រាប់ការតថ្លៃរបស់តក្កករ ជាមួយសហគ្រាសនោះ។ មានន័យថាប្រកាសនីយបត្រតក្កកម្មរបស់តក្កករ អាចជាចំណុចចាប់អារម្មណ៍មួយរបស់សហគ្រាសមួយ ផ្សេងទៀត ដែលតក្កករកំពុងចរចារជាមួយ ហើយតក្កករ អាចនឹងឈានទៅក្នុងការរៀបចំចាត់ចែងឱ្យមានការផ្តល់អាជ្ញាប័ណ្ណទៅវិញទៅមក។
- ***រូបភាពវិជ្ជមានរបស់សហគ្រាស*** ៖ ដៃគូអាជីវកម្ម ឬការបណ្តាក់ទុនវិនិយោគ និងម្ចាស់ភាគហ៊ុនអាចយល់ឃើញថា រូបភាពប្រកាសនីយបត្រតក្កកម្ម គឺជាការបង្ហាញនូវកម្រិតខ្ពស់ នៃជំនាញឯកទេសកម្ម និងសមត្ថភាពខាងបច្ចេកវិទ្យា ដែលមាននៅក្នុងក្រុមហ៊ុន ។ ប្រការនេះបញ្ជាក់បាន

នូវភាពមានប្រយោជន៍សម្រាប់ការអំពាវនាវ មូលនិធិ ការស្វែងរកដៃគូអាជីវកម្ម និងការបង្កើតតម្លៃទីផ្សារសម្រាប់សហគ្រាសបាន។

- **ជាពិសេសម្ចាស់ប្រកាសនីយបត្រតក្កកម្ម(តក្កករ)** មានសិទ្ធិក្នុងការហាមឃាត់ពីតតិយជនមិនឱ្យផលិត ប្រើប្រាស់ ដាក់លក់ ធ្វើសំណើលក់ ឬនាំចូលផលិតផលដោយពុំមានការអនុញ្ញាតពីម្ចាស់ប្រកាសនីយបត្រតក្កកម្មឡើយ។[24]

ដូចនេះហើយប្រកាសនីយបត្រតក្កកម្ម ត្រូវបានគេចាត់ទុកដូចជាយុទ្ធសាស្ត្រមួយដែលមាន ប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយកេរ្តិ៍ឈ្មោះ ព្រមទាំងពង្រីកទៅដល់កិត្យានុភាពរបស់សហគ្រាសដែលជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម ទៅកាន់សាធារណៈជនទាំងឡាយ និងដៃគូប្រកួតប្រជែងរបស់សហគ្រាស។ ជាពិសេសគឺផ្តល់ឥទ្ធិពលខ្ពស់ទៅកាន់ម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម នៅក្នុងទំនាក់ទំនងពាណិជ្ជកម្មជាមួយ និងដៃគូនានារបស់ខ្លួនផងដែរ។

## ផ្នែកទី ២៖ តក្កកម្មដែលអាច និងមិនអាចទទួលបានការការពារ

### ២.១. លក្ខខណ្ឌដែលតក្កកម្មអាចទទួលបានប្រកាសនីយបត្រតក្កកម្ម

តក្កកម្ម គឺសំដៅទៅការបង្កើតអ្វីដែលថ្មី ដែលជាគំនិតរបស់តក្កករ ដែលអាចយកទៅអនុវត្តបាន នៅក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិទ្យា។[25] ម្យ៉ាងវិញទៀតតក្កកម្មក៏អាចជាការមើលឃើញផលិតផល ឬដំណើរការផលិតកម្ម ឬអាចជាការមើលឃើញអ្វីមួយ ដែលទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម។[26] តក្កកម្ម ក៏ត្រូវបំពេញនូវលក្ខខណ្ឌជាច្រើនដើម្បីអាចនឹងទទួលបាននូវការការពារ។ អ្វីដែលសំខាន់នោះគឺ ការបង្កើត ឬការច្នៃប្រឌិតថ្មីទាំងនោះ ដែលរាល់កម្មវត្ថុរបស់វាត្រូវតែស្របទៅនឹងច្បាប់ ត្រូវតែថ្មី ត្រូវមានជំហាននៃការរកឃើញថ្មី និងអាចអនុវត្តបានក្នុងឧស្សាហកម្ម ហើយជាងនេះទៅទៀតគ្រប់ម្ចាស់ស្នាដៃត្រូវតែបង្ហាញពីការបង្កើតថ្មីរបស់ខ្លួនក្នុងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម និងត្រូវបំពេញទៅតាមលក្ខខណ្ឌតម្រូវផ្សេងទៀតដែលបានកំណត់ដោយច្បាប់។[27]

យោងតាមមាត្រា៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម បានចែងថាតក្កកម្មដែលតក្កករបានរកឃើញនោះត្រូវតែថ្មី មានជំហាននៃការរកឃើញថ្មី និងអាចយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម[28] ៖

---

[24] បណ្ឌិត "ទេព សុខ", "នីតិកម្មសិទ្ធបញ្ញា", ឆ្នាំសិក្សា២០២២-២០២៣។

[25] មាត្រា៣ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[26] លោក "កាន់ សុទ្ធប៉ូលីន", "នីតិកម្មសិទ្ធបញ្ញា"។

[27] បណ្ឌិត "ឃឹម គីរី", "នីតិកម្មសិទ្ធបញ្ញា", រក្សាសិទ្ធិ ឆ្នាំ២០១៩, កែសម្រួល ឆ្នាំ២០២២។

[28] មាត្រា៥ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

- តក្កកម្មនោះត្រូវតែថ្មី មានន័យថាតក្កកម្មនោះ មិនមានពីមុន ឬប្រើប្រាស់មកឡើយ។ ចំពោះតក្កកម្មដែលគេចាត់ទុកថាថ្មីនោះ លុះត្រាតែវាពុំទាន់បានរកឃើញដោយស្នាដៃសិប្បកម្មណាមួយតាមរយៈ ជាចំណេះដឹងដែលបានស្គាល់ ឬដឹងដោយសាធារណៈជនក៏ដូចជា ការផ្សព្វផ្សាយ ឬការប្រើប្រាស់តាមវិធីផ្សេងៗពីមុនមក។
- មានជំហាននៃការរកឃើញថ្មី សំដៅទៅលើជំហាននៃការច្នៃប្រឌិតរាល់តក្កកម្មដែលបង្កើតឡើងដោយបុគ្គលណាដែលមានកម្រិតជំនាញខ្ពស់ និងមិនអាចអោយបុគ្គលណាដែលមានកម្រិតមានកម្រិតជំនាញធម្មតាយល់ដឹងបាន។[29] ប្រសិនបើបុគ្គលក្នុងជំនាញសាមញ្ញធម្មតាអាចយល់ឃើញនូវជំហានទាំងនោះ តក្កកម្មនោះគឺមិនអាចទទួលបានប្រកាសនីយបត្រតក្កកម្មឡើយ។ ក្នុងន័យនេះគឺចង់សំដៅទៅលើរាល់តក្កកម្មដែលរកឃើញនោះ គឺមិនអាចយល់ឃើញដោយបុគ្គលសាមញ្ញឡើយលុះត្រាតែមានការពន្យល់យ៉ាងត្រឹមត្រូវពីតក្កករ។
- អាចអនុវត្តបានក្នុងវិស័យឧស្សាហកម្ម សំដៅទៅលើតក្កកម្មដែលអាចអនុវត្តបាននៅក្នុងវិស័យឧស្សាហសកម្ម ហើយត្រូវមានជាលក្ខណៈអាចអនុត្តបាន មិនមែនគ្រាន់តែជាទ្រឹស្តីនោះទេ។[30]
- តក្កកម្មត្រូវតែជាកម្មវត្ថុស្របច្បាប់ជាចាំបាច់ គឺត្រូវជាការបង្កើតថ្មីពីគំនិតប្រាជ្ញារបស់មនុស្ស ដែលការផលិតនោះមានភាពស្របច្បាប់ មានសារៈប្រយោជន៍សម្រាប់ការប្រើប្រាស់ ដោយអាចយកទៅធ្វើអាជីវកម្មបាន និងមិនត្រូវបានផាត់ចេញដោយច្បាប់ ឬមិនត្រូវបានច្បាប់ហាមឃាត់។
  ឧទាហរណ៍៖ ការរកឃើញនូវឧបករណ៍កែច្នៃ ឬផលិតគ្រឿងញៀន ដែលច្បាប់ហាមឃាត់។

### ២.២. តក្កកម្មដែលត្រូវបានផាត់ចេញដោយច្បាប់ និងមិនទទួលបានការការពារ

យោងតាមមាត្រា៤ និងមាត្រា៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម សុទ្ធសឹងតែចែងអំពីតក្កកម្មដែលមិនអាចផ្តល់ប្រកាសនីយបត្រតក្កកម្មបាន។ ចំពោះមាត្រា៤ បានកំណត់អំពីសញ្ញាណមួយចំនួនដែលមិនត្រូវផ្តល់នូវប្រកាសនីយបត្រតក្កកម្ម រួមមាន៖

- ការរកឃើញ ទ្រឹស្តីវិទ្យាសាស្ត្រ និងវិធីសាស្ត្រគណិតវិទ្យា។
- គម្រោងការ ឬវិធីសាស្ត្រសម្រាប់ធ្វើជំនួញសម្រាប់ធ្វើសកម្មភាពហ្វឹកហ្វឺនខាងប្រាជ្ញាសុទ្ធសាធ ឬសម្រាប់លេងល្បែងកំសាន្ត។

[29] មាត្រា៧ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។
[30] បណ្ឌិត "ទេព សុខ", "នីតិកម្មសិទ្ធបញ្ញា", ឆ្នាំសិក្សា២០២២-២០២៣។

- វិធីសាស្ត្រសម្រាប់ព្យាបាលរាងកាយមនុស្ស ឬសត្វ ដោយការវះកាត់ ឬដោយការព្យាបាល ក៏ដូចជាវិធីសាស្ត្រវិនិច្ឆ័យរោគដែលបានអនុវត្តលើរាងកាយ មនុស្ស ឬសត្វ។
- រុក្ខជាតិ ឬសត្វដែលមិនមែនជាមីក្រូសិរីរាង្គ និងដំណើរការកកើតទៅតាមលក្ខណៈជីវសាស្ត្រសំខាន់ៗ សម្រាប់ផលិតកម្មរុក្ខជាតិ ឬសត្វ។
- ប្រភេទផ្សេងៗនៃពូជរុក្ខជាតិណាមួយ។[31]

ចំណែកឯមាត្រា៩ ក៏បានចែងអំពីតក្កកម្មដែលការធ្វើអាជីវកម្មពាណិជ្ជកម្មនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ហើយមិនអាចប្រកាសនីយបត្រតក្កកម្មបានប្រសិនបើគេរកឃើញថាតក្កកម្មនោះ ៖

- ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌
- មិនការពារជីវិត ឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ
- ធ្វើឱ្យខូចបរិស្ថានធ្ងន់ធ្ងរ ឬ
- ត្រូវបានច្បាប់ហាមឃាត់។[32]

[31] មាត្រា៨ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[32] មាត្រា៩ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

# ជំពូកទី២

# នីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្មជាតិ និង អន្តរជាតិ

# ជំពូកទី២៖ នីតិវិធីនៃការចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិ

## ផ្នែកទី ១៖ នីតិវិធីនៃការចុះបញ្ជីតក្កកម្មជាតិ

សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម គឺជាកម្មសិទ្ធិរបស់តក្កករ។ ប្រសិនបើមានបុគ្គលពីរនាក់ ឬច្រើននាក់រួមគ្នាបង្កើតបានតក្កកម្មមួយសិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនេះ ត្រូវតែជាកម្មសិទ្ធិរួមគ្នានៃបុគ្គលទាំងឡាយនោះ។ ប្រសិនបើមានបុគ្គលពីរនាក់ ឬច្រើននាក់បានរកឃើញដោយឡែកៗពីគ្នា នូវតក្កកម្មមួយដូចគ្នា បុគ្គលណាបានដាក់សំណុំលិខិតស្នើសុំដែលមានកាលបរិច្ឆេទសុំចុះបញ្ជីមុនគេបង្អស់ ឬមានការបរិច្ឆេទអាទិភាពមុនគេបង្អស់ហើយបានប្រកាសសុពលភាពនៃកាលបរិច្ឆេទអាទិភាពនោះ ត្រូវទទួលសិទ្ធិជាម្ចាស់ប្រកាសនីយបត្រតក្កកម្ម ប្រសិនបើសំណុំលិខិតស្នើសុំខាងលើមិនត្រូវបានដកយកទៅវិញ ឬបោះបង់ចោល ឬក៏ត្រូវបដិសេធ។ សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម អាចប្រគល់ ឬផ្ទេរទៅឱ្យបុគ្គលដទៃដើម្បីស្នងជំនួសបាន។[33] តក្កករត្រូវតែដាក់ឈ្មោះរបស់ខ្លួននៅក្នុងប្រកាសនីយបត្រតក្កកម្ម លើកលែងតែតក្កករនោះបានចុះហត្ថលេខាលើសេចក្តីប្រកាស ជាលាយលក្ខណ៍អក្សរពិសេសមួយផ្ញើជូនមន្ត្រីកាន់កាប់បញ្ជីដោយបញ្ជាក់ថាខ្លួនពុំមានបំណងឱ្យដាក់ឈ្មោះរបស់ខ្លួនឡើយ ទើបនៅលើប្រកាសនីយបត្រតក្កកម្មនោះមិនត្រូវដាក់ឈ្មោះតក្កករ។ ការសន្យា ឬការទទួលរ៉ាប់រងណាមួយរបស់តក្កករ ដោយផ្ទាល់មាត់ធ្វើឡើងចំពោះបុគ្គលណាម្នាក់ដែលថាខ្លួននឹងធ្វើតាមសេចក្តីប្រកាសខាងលើនឹងពុំមានប្រសិទ្ធិភាពស្របច្បាប់ឡើយ។[34]

### ១.១. លក្ខខណ្ឌនៃការចុះបញ្ជី

ដើម្បីទទួលបាននូវការការពារ គ្រប់ការរកឃើញថ្មីទាំងឡាយ ដាច់ខាតត្រូវតែស្នើសុំចុះបញ្ជីដែលការចុះបញ្ជីនោះអាចជាការចុះបញ្ជីតក្កកម្មជាតិ និងការចុះបញ្ជីតក្កកម្មបរទេសអាស្រ័យលើការដាក់ពាក្យស្នើសុំរបស់តក្កករ ឬអ្នកដែលទទួលបានសិទ្ធិពីតក្កករ។ ការដាក់សុំណុំលិខិតស្នើសុំត្រូវតែមានការបង់កម្រៃតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ រដ្ឋមន្ត្រីត្រូវចេញបទបញ្ជាចាំបាច់ណែនាំលំអិតអំពីការអនុវត្តន៍ច្បាប់នេះ។ ចំពោះការបង់កម្រៃដែលទាក់ទងទៅនឹងការដាក់សំណុំខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវកំណត់ដោយសេចក្តីប្រកាសរួមរបស់ក្រសួងទទួលបន្ទុកឧស្សាហកម្ម និងក្រសួងទទួលបន្ទុកហិរញ្ញវត្ថុ។[35]

[33] មាត្រា១០ដល់មាត្រា១៣,នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[34] មាត្រា១៥,នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[35] មាត្រា១៦,នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

### ១.១.១. ការចុះបញ្ជីតក្កកម្មជាតិ

រាល់ការដាក់ពាក្យស្នើសុំចុះបញ្ជីតក្កកម្មជាតិ អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញពាក្យសុំ ដោយត្រូវភ្ជាប់មកជាមួយនូវសេចក្តីអធិប្បាយ សេចក្តីអះអាង និងខ្លឹមសារសង្ខេបអំពីតក្កកម្មនោះ ជាអាទិ៍។

**ក. ពាក្យសុំ**

ប្រកាសនីយបត្រតក្កកម្មជាតិ គឺតក្កកម្មទាំងឡាយណាដែលរកឃើញនៅក្នុងប្រទេសដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនោះ។ សំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្មអាចដាក់នៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ នៅក្នុងពាក្យសុំ អ្នកដាក់ពាក្យសុំត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអត្តសញ្ញាណនៃតក្កកម្ម ហើយនេះគឺជាកិច្ចដំបូងនៅក្នុងការរៀបចំនូវពាក្យសុំលិខិតស្នើសុំ រួមទាំងទិន្នន័យទាំងឡាយដែលពាក់ព័ន្ធ និងត្រូវភ្ជាប់មកជាមួយ នូវចំណងជើងនៃតក្កកម្មនោះ ។ ប្រសិនបើអ្នកដាក់ពាក្យសុំនោះមិនមែនជាតក្ករទេនោះ អ្នកដាក់ពាក្យសុំនោះត្រូវភ្ជាប់នូវឯកសារបញ្ជាក់ពីការផ្ទេរសិទ្ធិពីតក្ករមកជាមួយផង។[36] ពាក្យសុំត្រូវមានបញ្ជាក់អំពីអ្វីដែលអាចឈានទៅដល់ការផ្តល់ប្រកាសនីយបត្រតក្កកម្មបាន ដូចជានាម និងទិន្នន័យផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងអ្នកដាក់ពាក្យសុំជាតក្ករ និងភ្នាក់ងារតំណាងប្រសិនបើមាន និងចំណងជើងនៃតក្កកម្មនោះ។[37] ចំណងជើងនៃតក្កកម្មត្រូវតែខ្លីហើយច្បាស់លាស់។[38] ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ត្រូវបញ្ជាក់ ឈ្មោះ អាសយដ្ឋាន សញ្ជាតិ និងទីលំនៅរបស់អ្នកដាក់ពាក្យសុំម្នាក់ៗ និងត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំម្នាក់ៗ។ ក្នុងករណីអ្នកដាក់ពាក្យសុំជាតក្ករ ពាក្យសុំត្រូវតែភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់អំពីអានុភាពនោះ និងអាសយដ្ឋានរបស់តក្ករម្នាក់ៗ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំចំពោះប្រកាសនីយបត្រតក្កកម្ម។ ប្រសិនបើអ្នកដាក់ពាក្យសុំត្រូវបានតំណាងដោយភ្នាក់ងារ ពាក្យសុំត្រូវបញ្ជាក់ និងថ្លែងបញ្ជាក់ផងដែរនូវឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារនោះ។

**ខ. សេចក្តីអធិប្បាយ**

សេចក្តីអធិប្បាយត្រូវលើកបង្ហាញអំពីតក្កកម្មក្នុងលក្ខណៈច្បាស់លាស់និងពេញលេញដើម្បីឱ្យបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញអាចអនុវត្តបាននូវតក្កកម្មនោះ។ ដោយឡែកសេចក្តីអធិប្បាយនោះត្រូវចង្អុល

[36] បណ្ឌិត "ឃឹម គីរី", "នីតិកម្មសិទ្ធបញ្ញា"។

[37] មាត្រា១៧,នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[38] ប្រការ៦,នៃប្រកាស ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍។

បង្ហាញឱ្យដឹងនូវ វិធីដែលល្អជាងគេ ដើម្បីអនុវត្តតាមបាននូវតក្កកម្មខាងលើ នៅពេលចុះកាលបរិច្ឆេទសុំចុះបញ្ជី ឬនៅពេលចុះកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំក្នុងករណីអាទិភាពត្រូវបានអះអាង។[39]

សេចក្តីអធិប្បាយត្រូវមានលក្ខណៈដូចខាងក្រោម៖

➢ សេចក្តីអធិប្បាយត្រូវបញ្ជាក់ជាដំបូងនូវចំណងជើងនៃតក្កកម្មដូចមានបង្ហាញនៅក្នុងពាក្យសុំហើយត្រូវ៖

- រៀបរាប់ឱ្យបានច្បាស់លាស់អំពីផ្នែកបច្ចេកទេស ដែលពាក់ព័ន្ធទៅនឹងតក្កកម្ម។
- បញ្ជាក់អំពីស្នាដៃជាមូលដ្ឋានដែលបានដឹងចំពោះអ្នកពាក់ពាក្យសុំ អាចត្រូវចាត់ទុកថា អាចប្រើប្រាស់សម្រាប់ការយល់ដឹង ការស្រាវជ្រាវ និងការពិនិត្យតក្កកម្ម និងការដកស្រង់ឯកសារដែលឆ្លុះបញ្ចាំងស្នាដៃនោះ។
- បង្ហាញឱ្យដឹងពីតក្កកម្មនៅក្នុងលក្ខខណ្ឌដែលអាចយល់ដឹងបាននឹងបញ្ជាក់អានុភាពដ៏មានផលប្រយោជន៍របស់តក្កកម្ម ដោយយោងតាមស្នាដៃដែលជាមូលដ្ឋាននោះប្រសិនបើមាន។
- អធិប្បាយយ៉ាងសង្ខេបអំពីរូបគំនូរដែលបង្ហាញនៅក្នុងគំនូសបង្ហាញប្រសិនបើមាន ។
- កំណត់យកយ៉ាងហោចណាស់វិធីមួយបែបដែលល្អជាងគេបំផុត ដែលបានគិតទុកដោយអ្នកដាក់ពាក្យសុំសម្រាប់អនុវត្តតក្កកម្ម។ ករណីនេះត្រូវធ្វើឡើងក្នុងលក្ខខណ្ឌនៃឧទាហរណ៍ ប្រសិនបើសមស្រប ព្រមទាំងយោងទៅគំនូសបង្ហាញប្រសិនបើមាន។
- បញ្ជាក់ឱ្យបានជាក់លាក់នូវ របៀបដែលតក្កកម្មអាចយកទៅអនុវត្តបាន នៅក្នុងលក្ខណៈឧស្សាហកម្ម និងរបៀបដែលតក្កកម្មអាចត្រូវយកផលិត និងប្រើប្រាស់ ឬប្រសិនបើតក្កកម្មអាចត្រូវប្រើប្រាស់តែប៉ុណ្ណោះត្រូវបញ្ជាក់របៀបដែលអាចយកទៅប្រើប្រាស់នោះ នៅពេលដែលតក្កកម្មមានសភាពខុសប្លែកពីសេចក្តីអធិប្បាយ ឬពីលក្ខណៈរបស់តក្កកម្ម។

➢ របៀបរបប និងសណ្តាប់ធ្នាប់ដែលមានចែងក្នុងចំណុច ១ ខាងលើត្រូវអនុវត្តតាមលើកលែងតែនៅពេលណារបៀបរបបខុសគ្នា ឬសណ្តាប់ធ្នាប់ខុសគ្នានឹងផ្តល់ជាលទ្ធផលការយល់ដឹងកាន់តែប្រសើរឡើង និងការបង្ហាញកាន់តែសង្ខេបខ្លីថែមទៀត ព្រោះតែប្រភេទនៃតក្កកម្ម។[40]

[39] មាត្រា១៨ ,នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[40] ប្រការ៧ ,នៃប្រកាស ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍។

**គ. សេចក្តីអះអាង**

សេចក្តីអះអាងត្រូវតែកំណត់ឱ្យបានច្បាស់លាស់ អំពីចំណុចដែលសុំឱ្យមានការការពារ។ សេចក្តីអធិប្បាយ និងគំនូសបង្ហាញអាចត្រូវយកទៅប្រើប្រាស់បានសម្រាប់ធ្វើការបកស្រាយសេចក្តីអះអាងនោះ។ សេចក្តីអះអាងត្រូវតែច្បាស់លាស់ និងសង្ខេប។ សេចក្តីអះអាងនោះត្រូវតែផ្អែកទាំងស្រុងលើសេចក្តីអធិប្បាយ។[41]

សេចក្តីអះអាងត្រូវមានលក្ខណៈដូចខាងក្រោមនេះ ៖

- ចំនួននៃសេចក្តីអះអាងត្រូវតែមានលក្ខណៈសមស្របទៅតាមលក្ខណៈរបស់តក្កកម្ម។ ប្រសិនបើមានសេចក្តីអះអាងច្រើន ត្រូវចុះលេខរៀងតាមលំដាប់លំដោយជាលេខខ្មែរ។
- សេចក្តីអះអាងត្រូវកំណត់តក្កកម្មទៅតាមលក្ខណៈបច្ចេកទេសរបស់តក្កកម្មនោះ ។
- នៅពេលណាដែលសមស្របសេចក្តីអះអាងត្រូវមាន៖
  - សេចក្តីថ្លែងបញ្ជាក់អំពីលក្ខណៈបច្ចេកទេសពិសេសទាំងឡាយរបស់តក្កកម្មដែលចាំបាច់សម្រាប់ការកំណត់អត្ថន័យនៃតក្កកម្ម ក៏ប៉ុន្តែក្នុងការផ្សំបញ្ចូលគ្នា វាជាផ្នែកនៃស្ថានដែមុន ។
  - បង្ហាញលក្ខណៈផ្នែកដែលនាំមុខដោយពាក្យពេចន៍ "**បានស្តែងនូវលក្ខណៈដែលក្នុងនោះ....**" "បានស្តែងនូវលក្ខណៈដោយ ...." **ដែលនៅក្នុងនោះការធ្វើឱ្យប្រសើរឡើងមាន** ឬពាក្យពេចន៍ណាមួយផ្សេងទៀតដែលមានអានុភាពដូចគ្នា ដែលថ្លែងយ៉ាងសង្ខេបអំពីលក្ខណៈបច្ចេកទេសដែលផ្សំបញ្ចូលគ្នាជាមួយលក្ខណៈទាំងឡាយដែលមានចែងនៅក្នុងចំណុចខាងលើគឺមានបំណងចង់ការពារ។
- លើកលែងតែករណីចាំបាច់ដាច់ខាត សេចក្តីអះអាងមិនត្រូវសំអាងលើលក្ខណៈ បច្ចេកទេសរបស់តក្កកម្មអំពីការយោងលើសេចក្តីអធិប្បាយ ឬគំនូសបង្ហាញ។ ជាពិសេស សេចក្តីអះអាង មិនត្រូវសំអាងលើការយោងទាំងនេះទេ ដូចជា **ដូចបានពោលនៅក្នុងផ្នែក... នៃសេចក្តីអធិប្បាយ" ឬ " ដូចបានបង្ហាញនៅក្នុងរូបគំនូរ...នៃគំនូសបង្ហាញ** ។
- ក្នុងករណីដែលសំណុំលិខិតស្នើសុំ មានគំនូសបង្ហាញលក្ខណៈបច្ចេកទេសដែលបានបញ្ជាក់នៅក្នុងសេចក្តីអះអាង ត្រូវដាក់តាមលំដាប់លំដោយយ៉ាងសមស្រប ដោយសញ្ញាយោងពាក់ព័ន្ធទៅនឹងលក្ខណៈទាំងនោះ។ នៅពេលដែលប្រើប្រាស់សញ្ញាយោង ត្រូវដាក់យ៉ាងសមស្រប នៅក្នុងវង់ក្រចក។

[41] មាត្រា១៩,នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម, អនុម័តនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០២។

ប្រសិនបើការបញ្ចូលសញ្ញាយោងមិនជួយសម្រួលជាពិសេសឱ្យងាយយល់ឆាប់រហ័សអំពីសេចក្តីអះអាងទេនោះសញ្ញាយោងនេះមិនត្រូវយកមកប្រើប្រាស់ទេ។

- សេចក្តីអះអាងណាមួយដែលបានយកមកដាក់ក្រោយកាលបរិច្ឆេទសុំចុះបញ្ជី របស់សំណុំលិខិតស្នើសុំ ហើយដែលមិនបានបញ្ជាក់ប្រាប់ជាមួយនឹងសេចក្តីអះអាងដែលលេចចេញ ពីមុននៅក្នុងសំណុំលិខិតស្នើសុំ ត្រូវយកមកដាក់ជាសេចក្តីអះអាងកែសម្រួល ឬជាសេចក្តីអះអាងថ្មីអាស្រ័យលើការ ជ្រើសរើសយករបស់អ្នកដាក់ពាក្យសុំ ។
- ការលុបចោលសេចក្តីអះអាងណាមួយដែលលេចចេញមុននៅក្នុងសំណុំលិខិតស្នើសុំត្រូវតែធ្វើឡើងដោយបញ្ជាក់លេខនៃសេចក្តីអះអាងពីមុននោះដោយប្រើពាក្យ **“លុបចោល”**។[42] គំនូសបង្ហាញចាំបាច់ត្រូវតែមានដើម្បីយកមកបកស្រាយពន្យល់អំពីតក្កកម្មនោះ។[43]

**ឃ. ខ្លឹមសារសង្ខេប**

ខ្លឹមសារសង្ខេបត្រូវបកស្រាយត្រឹមតែគោលបំណងនៃពត៌មានបច្ចេកទេសប៉ុណ្ណោះ មិនត្រូវបកស្រាយអំពីវិសាលភាពនៃការការពារឡើយ។ អ្នកដាក់ពាក្យសុំ អាចដកសំណុំលិខិតស្នើសុំ ទៅវិញនៅពេលណាក៏បានក្នុងករណីដែលសំណុំលិខិតស្នើសុំនោះស្ថិតក្នុងរយៈពេលព្យួរទុកសម្រាប់ពិនិត្យដើម្បីផ្តល់ប្រកាសនីយបត្រតក្កកម្ម។[44] ខ្លឹមសារសង្ខេប ត្រូវតែមានលក្ខណៈដូចខាងក្រោម៖

- ខ្លឹមសារសង្ខេបត្រូវតែបានព្រាងឡើងដែលអាចយកទៅប្រើដោយប្រសិទ្ធិភាពដូចជា ឧបករណ៍ស្កេនសម្រាប់គោលបំណងនៃការស្រាវជ្រាវនៅក្នុងស្នាដៃជាក់លាក់។
- ខ្លឹមសារសង្ខេបត្រូវរួមមាន៖
    - សេចក្តីសង្ខេបនៃការបញ្ចេញឱ្យដឹងមានរៀបរាប់នៅក្នុងសេចក្តីអធិប្បាយ សេចក្តីអះអាង និងគំនូសបង្ហាញណាមួយដែលបញ្ជាក់ផ្នែកបច្ចេកទេសពាក់ព័ន្ធទៅនឹងតក្កកម្ម និងត្រូវធ្វើយ៉ាងណាឱ្យងាយយល់អំពីបញ្ហាបច្ចេកទេស សារៈសំខាន់នៃដំណោះស្រាយរបស់បញ្ហានោះតាម រយៈតក្កកម្ម និងគោលការណ៍ប្រើប្រាស់តក្កកម្ម ឬការប្រើប្រាស់តក្កកម្ម។
    - ក្នុងករណីចាំបាច់ រូបមន្តគីមីដែលស្តែងល្អជាងគេរបស់តក្កកម្មក្នុងចំណោមរូបមន្តទាំងឡាយដែលមាននៅក្នុងសំណុំលិខិតស្នើសុំ។
- ខ្លឹមសារសង្ខេបត្រូវ បរិយាយឱ្យខ្លីមិនឱ្យលើសពី១៥០ (មួយរយហាសិប) ពាក្យ។

[42] ប្រការ១១ ,នៃប្រកាស ស្តីពីការគ្រប់គ្រង និងនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍។

[43] មាត្រា២០,នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[44] មាត្រា២១ និងមាត្រា២២,នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

- ខ្លឹមសារសង្ខេបមិនត្រូវមានសេចក្តីថ្លែងអំពីអង្គសេចក្តីដែលបានអះអាង ឬតម្លៃនៃតក្កកម្ម ឬអំពីការអនុវត្ត ដោយមិនប្រាកដចំពោះតក្កកម្ម។
- លក្ខណៈបច្ចេកទេសសំខាន់ៗនីមួយៗដែលរៀបរាប់នៅក្នុងខ្លឹមសារសង្ខេប និងដែលបានពន្យល់ ដោយគំនូសបង្ហាញនៅក្នុងសំណុំលិខិតស្នើសុំត្រូវតែកត់សម្គាល់ដោយសញ្ញាយោងហើយដាក់នៅក្នុងវង់ក្រចក។
- ខ្លឹមសារសង្ខេប ត្រូវតែភ្ជាប់មកជាមួយនូវគំនូសបង្ហាញណាមួយដែលពន្យល់។[45]

**ង. ការរួមបញ្ចូល និងការបំបែកសំណុំលិខិតស្នើសុំ**

សំណុំលិខិតស្នើសុំត្រូវពាក់ព័ន្ធទៅនឹងតក្កកម្មតែមួយគត់ ឬតក្កកម្មមួយក្រុមដែលទាក់ទងគ្នាបង្កើតបានជាទស្សនៈរួមមួយនៃតក្កកម្មនោះ។

មុនពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យសុំអាចកែតម្រូវសំណុំលិខិតស្នើសុំរបស់ខ្លួនបាន ប៉ុន្តែការកែតម្រូវនោះមិនត្រូវបន្ថែមអ្វីឱ្យលើសពីខ្លឹមសារដែលបានបញ្ជាក់នៅក្នុងសំណុំលិខិតស្នើសុំពីដំបូងឡើយ។

មុនពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យសុំ អាចសុំបំបែកសំណុំលិខិតស្នើសុំជាពីរ ឬច្រើនបានដែលហៅថាសំណុំលិខិតស្នើសុំបំបែក។ ប៉ុន្តែសំណុំលិខិតស្នើសុំបំបែកនោះ មិនត្រូវបន្ថែមអ្វីឱ្យលើសពីខ្លឹមសារ ដែលបានបញ្ជាក់នៅក្នុងសំណុំលិខិតស្នើសុំពីដំបូងឡើយ។

សំណុំលិខិតស្នើសុំបំបែកនីមួយៗ ត្រូវទទួលបានកាលបរិច្ឆេទសុំចុះបញ្ជី និងកាលបរិច្ឆេទអាទិភាពដូចសំណុំលិខិតស្នើសុំពីដំបូងដែរ។

ក្នុងករណីដែលប្រកាសនីយបត្រតក្កកម្មមួយ ត្រូវផ្តល់រួចហើយទៅតាមសំណុំលិខិតស្នើសុំដែលមិនបានបំពេញតាមលក្ខខណ្ឌតម្រូវ នៃការរួមបញ្ចូលតែមួយនៃតក្កកម្មដូចបានចែងនៅក្នុងមាត្រា២៣ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម មិនត្រូវចាត់ទុកជាមូលហេតុនៃអសុពលភាពរបស់ប្រកាសនីយបត្រតក្កកម្មនោះបានឡើយ។[46]

**១.១.២. ការចុះបញ្ជីតក្កកម្មបរទេស**

ប្រកាសនីយបត្រតក្កកម្មបរទេស គឺមានន័យថាតក្កកម្មដែលរកឃើញនោះ មិនស្ថិតនៅក្នុងប្រទេសដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មឡើយ។

សំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្មអាចដាក់នៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ សំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្មអាច អះអាង

[45] ប្រការ១៣ ,នៃប្រកាស ស្តីពីការគ្រប់គ្រង និងនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍។
[46] មាត្រា២៣ ដល់មាត្រា២៦,នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

អំពីអាទិភាពនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនគេនៅក្នុងប្រទេស ឬនៅក្នុងតំបន់ ឬនៅអន្តរជាតិ ដោយយោងតាមអនុសញ្ញាទីក្រុងប៉ារីស និងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម។[47] ក្នុងករណីនេះនាយកដ្ឋានកម្មសិទ្ធិឧស្សាកម្ម និងស្នើសុំឯកសារចម្លង នៃសំណុំលិខិតស្នើសុំដែលបានដាក់មុនគេ ដោយមានការបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ក៏ដូចជា របាយការណ៍ស្រាវជ្រាវ ឬលទ្ធផលនៃការពិនិត្យ ឬសេចក្តីសម្រេច ផ្សេងៗរបស់ការិយាល័យដែលទទួលសំណុំលិខិតស្នើសុំនោះ។[48]

**ក. ឯកសារតម្រូវ**

អ្នកដាក់ពាក្យសុំត្រូវផ្តល់ដល់មន្ត្រីកាន់កាប់បញ្ជីតាមពេលវេលាកំណត់នូវឯកសារចម្លងនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនគេ និងត្រូវមានការបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមដោយការិយាល័យដែលបានទទួលសំណុំខិតស្នើសុំនោះ។[49]

ពាក្យសុំប្រកាសនីយបត្រតក្កកម្មត្រូវធ្វើជាភាសាខ្មែរ ដោយភ្ជាប់មកជាមួយនូវសេចក្តីអធិប្បាយអំពី តក្កកម្ម សេចក្តីអះអាងមួយ ឬច្រើនគំនូសបង្ហាញក្នុងករណីចាំបាច់ដើម្បីអោយងាយយល់អំពីតក្កកម្មនោះ ខ្លឹមសារសង្ខេប នឹងកម្រៃសេវាសាធារណៈ។ សេចក្តីអធិប្បាយត្រូវលើកបង្ហាញអំពីតក្កកម្មក្នុងលក្ខណៈច្បាស់លាស់ និងពេញលេញ ដើម្បីអោយបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញអាចអនុវត្តបាននូវ តក្កកម្មនោះ។

ប្រសិនបើ ពាក្យស្នើសុំអះអាង អំពីសិទ្ធិអាទិភាពនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនគេ ឯកសារចម្លងនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនគេនោះ ត្រូវតម្រូវអោយមាន និងត្រូវដាក់ក្នុងរយៈពេល ៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទស្នើសុំ របស់មន្ត្រីកាន់កាប់បញ្ជី។ ក្នុងករណីដែលសំណុំលិខិតស្នើសុំដំបូង សរសេរជាភាសាផ្សេងក្រៅពីភាសាខ្មែរអ្នកដាក់ពាក្យសុំត្រូវផ្តល់ សេចក្តីបកប្រែ សំណុំលិខិតស្នើសុំនោះជាភាសាខ្មែរក្នុងរយៈពេល៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំរបស់មន្ត្រីកាន់កាប់បញ្ជី។

សម្រាប់គោលបំណងនៃការស្រាវជ្រាវ និងការពិនិត្យសំណុំលិខិតស្នើសុំដែលសរសេរជាភាសាបរទេសក្រៅពីភាសាអង់គ្លេសត្រូវបកប្រែជាភាសាអង់គ្លេស ហើយត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៦(ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការសុំចុះបញ្ជី។ ក្នុងករណីដែលភ្នាក់ងារប្រកាសនីយបត្រតក្កកម្មកម្ពុជា ត្រូវបានចាត់តាំង នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនឹងតម្រូវអោយមានលិខិតប្រគល់សិទ្ធិ។ឯកសារបញ្ជាក់អំពីសិទ្ធិរបស់

---

[47] មាត្រា២៧, នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[48] Abacus IP CAMBODIA, https://vannarachincom.files.wordpress.com/2015/11/e19e98e19e82e19f92e19e82e19e91e19f81e19e9fe19e80e19f8de19ea2e19f86e19e96e19eb8e19e85e19f92e19e94e19eb6e19e94e19f8be19e94e19f92e19e9a.pdf

[49] មាត្រា២៨, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

អ្នកដាក់ពាក្យដែលមានបញ្ជាក់ភាពស្របច្បាប់ពីមន្ទីសាការីសាធារណៈ ក៏ត្រូវដាក់ជូននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មដែរ ប្រសិនបើអ្នកដាក់ពាក្យសុំមិនមែនជាតក្កករទេនោះ។ លិខិតប្រគល់សិទ្ធិ និងឯកសារបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យដែលមានបញ្ជាក់ភាពស្របច្បាប់ពីមន្ទីសាការីសាធារណៈ ព្រមទាំង ឯកសារចម្លងនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនគដោយមានការបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម អាចដាក់ជូនមន្ត្រីកាន់កាប់បញ្ជីជាមួយពាក្យ ស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ឬនៅពេលក្រោយបាន។ មន្ត្រីកាន់កាប់បញ្ជី នឹងចេញលិខិតស្នើសុំឯកសារទាំងនោះក្នុងរយៈពេល២សប្តាហ៍ ក្រោយកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។[50]

- អ្នកដាក់ពាក្យសុំត្រូវតែផ្តល់ជូនមន្ត្រីកាន់កាប់បញ្ជីនូវឯកសារដែលពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំនៅឯបរទេស ដែលបានដាក់នៅប្រទេសណាមួយ ឬច្រើនដូចខាងក្រោម៖
  - ឯកសារចម្លងនៃលិខិតឆ្លងឆ្លើយដែលពាក់ព័ន្ធទៅនឹងលទ្ធផលនៃការស្រាវជ្រាវ ឬលទ្ធផលនៃការពិនិត្យសំណុំលិខិតស្នើសុំនៅឯបរទេស ដែលអ្នកដាក់ពាក្យសុំបានទទួល។
  - ឯកសារចម្លងនៃប្រកាសនីយបត្រតក្កកម្ម ដែលបរទេសបានផ្តល់ជូនតាមការដាក់សំណុំលិខិតស្នើសុំនៅឯបរទេស។
  - ឯកសារចម្លងនៃសេចក្តីសម្រេចចុងក្រោយដែលបដិសេធ មិនទទួលសំណុំលិខិតស្នើសុំនៅឯបរទេស ឬបដិសេធមិនផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្មតាមសំណើនៃសំណុំលិខិតស្នើសុំនោះ។

នៅពេលមានសំណើពីមន្ត្រីកាន់កាប់បញ្ជី អ្នកដាក់ពាក្យសុំត្រូវផ្តល់នូវឯកសារចម្លងនៃសេចក្តីសម្រេចចុងក្រោយស្តីអំពីអសុពលភាពនៃប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ជូនផ្អែកតាមការដាក់សំណុំលិខិតស្នើសុំនៅឯបរទេស។[51]

សម្រាប់តក្កកម្មដែលធ្លាប់បានទទួលប្រកាសនីយបត្រតក្កកម្មនៅបរទេស អ្នកស្នើសុំត្រូវបន្ថែមនូវឯកសារមួយចំនួនផ្សេងទៀតដូចជា៖ សេចក្តីអះអាងអំពីសិទ្ធិអាទិភាពស្របតាមអនុសញ្ញាទីក្រុងប៉ារីសដើម្បីអាចទទួលបានសិទ្ធិអាទិភាពក្នុងពេល១២ (ដប់ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទចុះបញ្ជីលើកទី១ មកព្រមទាំងសំណុំលិខិត

---

[50] Abacus IP CAMBODIA, https://vannarachincom.files.wordpress.com/2015/11/e19e98e19e82e19f92e19e82e19e91e19f81e19e9fe19e80e19f8de19ea2e19f86e19e96e19eb8e19e85e19f92e19e94e19eb6e19e94e19f8be19e94e19f92e19e9a.pdf

[51] មាត្រា៣១, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

ដែលបានស្នើសុំចុះបញ្ជីនៅបរទេសនោះ និងប្រកាសនីយបត្រតក្កកម្មបរទេសដែលបានចុះបញ្ជីរួចរាល់នោះស្រប តាមកិច្ចព្រមព្រៀង TRIPS ។[52]

**ខ. កាលបរិច្ឆេទនៃការចុះបញ្ជី**

មន្ត្រីកាន់កាប់បញ្ជី ត្រូវទទួលស្គាល់កាលបរិច្ឆេទនៃការទទួលសំណុំលិខិត ស្នើសុំថាជាកាលបរិច្ឆេទនៃការសុំចុះបញ្ជីសំណុំលិខិតស្នើសុំបាន លុះត្រាតែនៅពេលដែលទទួលនោះ សំណុំលិខិតមានអមដោយឯកសារត្រឹមត្រូវដូចខាងក្រោម៖

- ការបញ្ជាក់យ៉ាងច្បាស់លាស់ ឬគ្រប់គ្រាន់អំពីបំណងនៃការសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម។
- ការបញ្ជាក់អំពីអត្តសញ្ញាណនៃអ្នកស្នើសុំ។
- ផ្នែកមួយនៃសំណុំលិខិតស្នើសុំដែលនៅលើផ្នែកនោះមានបញ្ជាក់នូវសេចក្តីអធិប្បាយរបស់តក្កកម្ម។

នៅពេលបានទទួលសំណុំលិខិតស្នើសុំ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាសំណុំលិខិតស្នើសុំនោះមិនបានបំពេញត្រឹមត្រូវទៅតាមលក្ខខណ្ឌតម្រូវមន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវទៅតាមលក្ខខណ្ឌតម្រូវនោះ និងកត់ត្រាកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំទៅតាមកាលបរិច្ឆេទដែលបានទទួលការកែតម្រូវ។ ប៉ុន្តែប្រសិនបើសំណុំលិខិត ស្នើសុំមិនបានកែតម្រូវទៅតាមការណែនាំសំណុំលិខិតស្នើសុំទេនោះ ត្រូវបានចាត់ទុកថាដូចជាមិនបានសុំចុះបញ្ជីឡើយ។[53]

បន្ទាប់ពីបានយល់ព្រមលើ កាលបរិច្ឆេទសុំចុះបញ្ជីមន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យមើលសំណុំលិខិតស្នើសុំនោះឱ្យបំពេញត្រឹមត្រូវទៅតាមលក្ខខណ្ឌតម្រូវដែលបានចែងនៅក្នុងមាត្រា១៦ និងមាត្រា១៧ នៃច្បាប់នេះ និងលក្ខខណ្ឌតម្រូវនានាដែលបានកំណត់ជាបទបញ្ជាចាំបាច់។ ក្នុងករណីដែលសំណុំលិខិតស្នើសុំ និងប្រកាសនីយបត្រតក្កកម្មមានទំនាក់ទំនងនឹងបរទេសមន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យមើលឱ្យគ្រប់គ្រាន់បន្ថែមទៀតអំពីពត៌មាននៃលក្ខខណ្ឌតម្រូវដែលមានចែងនៅក្នុងមាត្រា៣០ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។[54]

**គ. មន្ត្រីកាន់កាប់បញ្ជី**

មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យមើលសំណុំលិខិតស្នើសុំនោះ ឱ្យបំពេញត្រឹមត្រូវទៅតាមលក្ខខណ្ឌតម្រូវដែលបានកំណត់ដោយច្បាប់។ ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា សំណុំលិខិតស្នើសុំបានបំពេញ

---

52 បណ្ឌិត "ទេពសុខ", នីតិកម្មសិទ្ធិបញ្ញា, ទំព័រ២៨។

53 មាត្រា៣៣, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

54 មាត្រា៣៥, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

តាមលក្ខខណ្ឌតម្រូវដូចបានកំណត់ក្នុងមាត្រា៣៥ នៃច្បាប់នេះរួចហើយមន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យបន្ត ទៀតនូវលក្ខខណ្ឌតម្រូវដែលបានកំណត់នៅក្នុងមាត្រា៣ លក្ខខណ្ឌតម្រូវនៅក្នុងមាត្រា៤ ដល់មាត្រា៩ មាត្រា១៨ ដល់មាត្រា២០ មាត្រា២៣ដល់មាត្រា២៦ នៃច្បាប់នេះ និងបទបញ្ញាទាំងឡាយដែលពាក់ព័ន្ធនឹងច្បាប់នេះ។

- មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យបន្ថែមនូវ ចំណុចដូចខាងក្រោមនេះ៖
    - លទ្ធផលនៃរបាយការណ៍ស្រាវជ្រាវរបស់អន្តរជាតិ និងលទ្ធផលរបាយការណ៍ពិនិត្យជំហានដំបូង របស់អន្តរជាតិ ដែលធ្វើឡើងតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មរបស់ សំណុំលិខិតស្នើសុំ
    - របាយការណ៍ស្រាវជ្រាវ និងរបាយការណ៍ពិនិត្យដែលបានចែងនៅក្នុងមាត្រា៣១ ឬសេចក្តី សម្រេចចុងក្រោយ ដែលបានចែងនៅក្នុងចំណុច គ មាត្រា៣១
    - របាយការណ៍ស្រាវជ្រាវ និងរបាយការណ៍ពិនិត្យដែលបានធ្វើឡើងដោយស្ថាប័នស្រាវជ្រាវ និងពិនិត្យនៅក្រៅប្រទេសតាមសំណើរបស់មន្ត្រីកាន់កាប់បញ្ជី។[55]

ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាត្រឹមត្រូវតាមលក្ខខណ្ឌហើយនោះ មន្ត្រីកាន់កាប់ត្រូវដំណើរ ការផ្តល់ប្រកាសនីយបត្រតក្កកម្មជូនអ្នកដាក់ពាក្យសុំ។

- នៅពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម មន្ត្រីកាន់កាប់បញ្ជីត្រូវ៖
    - ចុះផ្សាយសេចក្តីបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម
    - ចេញលិខិតបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្មមួយច្បាប់ និងប្រកាសនីយបត្រតក្កកម្ម ចម្លងមួយច្បាប់ជូនដល់អ្នកដាក់ពាក្យសុំ
    - កត់ត្រាប្រកាសនីយបត្រតក្កកម្មនៅក្នុងបញ្ជី
    - ច្បាប់ចម្លងនៃប្រកាសនីយបត្រតក្កកម្មត្រូវមានសម្រាប់សាធារណៈជនសម្រាប់ជាវតាមតម្លៃ ដែលបានកំណត់។[56]

ដើម្បីសម្រួលដល់ការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មបរទេស កម្ពុជាបានចុះអនុស្សរណៈ នៃការយោគយល់គ្នាជាមួយបណ្តាប្រទេសសមាជិកអាស៊ានមួយចំនួនដោយតក្កករនៃប្រទេសទាំងនោះមិន ចាំបាច់ធ្វើដំណើរដោយផ្ទាល់មកដាក់ពាក្យស្នើសុំនៅក្នុងប្រទេសកម្ពុជានោះទេ ហើយតក្កករនៃប្រទេសកម្ពុជាក៏ មិនចាំបាច់ធ្វើដំណើរទៅដាក់ពាក្យស្នើសុំនៅតាមបណ្តាប្រទេសទាំងនោះវិញដែរ។ ការដាក់ពាក្យស្នើសុំ គឺអាចធ្វើ

[55] មាត្រា៣៦ មាត្រា៣៧,ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[56] មាត្រា៣៨ មាត្រា៣៩, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

នៅតាមអង្គភាព ឬស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីប្រកាសនីយបត្រតក្កកម្មបរទេសនៃប្រទេសនីមួយៗនោះតែម្តង ដោយត្រូវអនុលោមតាមបទប្បញ្ញត្តិនៃប្រទេសដែលត្រូវស្នើសុំចុះបញ្ជីនោះ។

**ឧទាហរណ៍៖** អង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍កម្ពុជាបានចុះអនុស្សរណៈនៃការយោគយល់គ្នា អនុញ្ញាតអោយមានការដាក់ពាក្យស្នើសុំ ប្រកាសនីយបត្រតក្កកម្មប្រទេសកម្ពុជា តាមរយៈអាជ្ញាធរសិង្ហបុរី ឬក៏ដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មប្រទេសសិង្ហបុរី តាមរយៈអាជ្ញាធរកម្ពុជាបាន។ អនុស្សរណៈនៃការយោគយល់គ្នាមានសុពលភាព ៥ (ប្រាំ) ឆ្នាំ ចាប់ពីថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៥ និងអាចត្រូវបន្តជាថ្មីបានដោយមានការព្រមព្រៀងគ្នាពីភាគីទាំងពីរ។ ក្រោយមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានចេញនូវប្រកាសមួយសម្រាប់អនុវត្តអនុស្សរណៈនោះនៅថ្ងៃទី២៥ ខែកក្កដាឆ្នាំ២០១៦ ដោយអ្នកដាក់ពាក្យសុំផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាអាចធ្វើតាមរយៈអង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី។ ដើម្បីទទួលបានការចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា អ្នកដាក់ពាក្យសុំត្រូវមានប្រកាសនីយបត្រតក្កកម្ម ដែលបានផ្តល់ក្នុងប្រទេសសិង្ហបុរី ជាមុនសិន។ ប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ត្រូវតែមានសុពលភាពការពារក្នុងអំឡុងពេលនៃការដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រ តក្កកម្មនៅកម្ពុជា ហើយប្រកាសនីយបត្រតក្កកម្មត្រូវមានកាលបរិច្ឆេទសុំចុះបញ្ជីនៅថ្ងៃ ឬក្រោយថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣។ ពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ត្រូវធ្វើឡើងនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយភ្ជាប់ជាមួយកម្រៃនៃការដាក់ពាក្យ ច្បាប់ថតចម្លងវិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ឯកសារចម្លងសេចក្តីពណ៌នាលម្អិតនៃប្រកាសនីយបត្រតក្កកម្មថតចម្លង ខ្លឹមសារសង្ខេប ដោយមានការបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ច្បាប់ដើមលិខិតផ្ទេរសិទ្ធិតំណាងដោយមានបញ្ជាក់ពីមន្ទីសាការីសាធារណៈ ប្រសិនបើអ្នកដាក់ពាក្យសុំត្រូវតំណាងដោយភ្នាក់ងារ។ ទោះបីជាច្បាប់ថតចម្លងវិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ដោយមានការបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមតម្រូវអោយមានក៏ដោយ ក៏មន្ត្រីកាន់កាប់បញ្ជីនៅតែត្រួតពិនិត្យដោយផ្អែកទៅលើច្បាប់ប្រកាសនីយបត្រតក្កកម្មរបស់ខ្លួន និងបទបញ្ញត្តិទូទៅផ្សេងទៀត។ ឯកសារបកប្រែជាភាសាខ្មែរត្រូវផ្តល់ជូនការិយាល័យប្រកាសនីយបត្រតក្កកម្មក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម។ កម្រៃចុះបញ្ជី និងកម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជាត្រូវបង់ក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទជូនដំណឹងបង់ប្រាក់។ សិទ្ធិទទួលបានពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរី នៅកម្ពុជាមិនត្រូវអនុវត្តចំពោះសិទ្ធិដែលមានមុនកាលបរិច្ឆេទសុំចុះបញ្ជីទទួលស្គាល់ ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅប្រទេសកម្ពុជាឡើយ។ បុគ្គលដែលប្រើប្រាស់តក្កកម្ម ឬធ្វើអាជីវកម្មលើតក្កកម្មនោះ មានសិទ្ធិបន្តធ្វើសកម្មភាពនោះដដែល ទោះបីជាប្រកាសនីយបត្រតក្កកម្មសិង្ហបុរី

នោះត្រូវបានទទួលចុះបញ្ជីនៅកម្ពុជាក៏ដោយ។ សេចក្តីសម្រេចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ពាក់ព័ន្ធនឹងការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មអាចជាកម្មវត្ថុប្តឹងតវ៉ាទៅតុលាការសមត្ថកិច្ចបានក្នុងរយៈពេល ៣ (បី) ខែ ចាប់ពីថ្ងៃចេញសេចក្តីសម្រេច។

## ១.២. ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងការការពារ

### ១.២.១. សិទ្ធិដែលបានប្រគល់តាមរយៈប្រកាសនីយបត្រតក្កកម្ម

ការធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជារាល់តក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយដោយបុគ្គលដទៃទៀតចាំបាច់ត្រូវតែមានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្មនោះ។ ក្នុងន័យនេះការធ្វើអាជីវកម្មនៃតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយ គឺមានន័យថាជាសកម្មភាពណាមួយនៃសកម្មភាពទាំងឡាយខាងក្រោមនេះ ៖

- ចំពោះផលិតផលណាមួយ ដែលបានផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្មរួចហើយការធ្វើអាជីវកម្មគឺ៖
  - ការផលិត ការនាំចូល ការផ្គត់ផ្គង់សម្រាប់ការលក់ និងការប្រើប្រាស់ផលិតផលនោះ
  - ការស្តុកទុកផលិតផលនោះ ក្នុងគោលបំណងផ្គត់ផ្គង់សម្រាប់លក់ ឬប្រើប្រាស់
- ចំពោះដំណើរការផលិតកម្មមួយដែលបានផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្មរួចហើយការធ្វើអាជីវកម្មគឺជា៖
  - ការប្រើប្រាស់ដំណើរការផលិតកម្មនោះ
  - ការធ្វើសកម្មភាពណាមួយនៃសកម្មភាពទាំងឡាយ ដូចមានចែងខាងលើនេះលើផលិតផលដែលទទួលបានដោយផ្ទាល់ពីមធ្យោបាយនៃដំណើរការផលិតកម្មនោះ។[57]

ម្ចាស់ប្រកាសនីយបត្រតក្កកម្មមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចចំពោះបុគ្គលណាដែលរំលោភ លើប្រកាសនីយបត្រតក្កកម្មរបស់ខ្លួន តាមរយៈការអនុវត្តន៍សកម្មភាពណាមួយដោយគ្មានការយល់ព្រមពីម្ចាស់ ឬមានសិទ្ធិប្តឹងចំពោះបុគ្គលណាដែលអនុវត្តសកម្មភាពទាំងឡាយដែលអាចនឹងបណ្តាលឱ្យមានការរំលោភដូចគ្នានេះកើតឡើង ។

- សិទ្ធិដែលបានប្រគល់តាមរយៈប្រកាសនីយបត្រតក្កកម្មមិនអនុវត្តចំពោះ៖
  - សកម្មភាពពាក់ព័ន្ធនឹងសម្ភារៈ ដែលបានដាក់តាំងនៅលើទីផ្សារ នៃព្រះរាជាណាចក្រកម្ពុជា ឬនៅលើទីផ្សារក្រៅព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ប្រកាសនីយបត្រតក្កកម្ម ឬដោយមានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម

[57] មាត្រា៤១ មាត្រា៤២, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

- ការប្រើប្រាស់សម្ភារៈនៅលើអាកាសយានដ្ឋាន យានយន្តផ្លូវគោក ឬនាវារបស់ប្រទេសដទៃ ដែលចូលចតជាបណ្តោះអាសន្ន ឬចូលចតដោយឧបទ្ទវហេតុក្នុងដែនអាកាស ដែនគោក ឬដែនទឹកនៃព្រះរាជាណាចក្រកម្ពុជា
- សកម្មភាពដែលធ្វើត្រឹមតែក្នុងគោលបំណងពិសោធន៍ ដែលទាក់ទងទៅនឹងតក្កកម្មដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្មរួចហើយ
- សកម្មភាពដែលប្រព្រឹត្តក្នុងគោលបំណងល្អ ដោយបុគ្គលណាម្នាក់ដោយប្រើប្រាស់តក្កកម្ម ឬក៏ធ្វើការរៀបចំឱ្យមានប្រសិទ្ធភាព និងហ្មត់ចត់នូវតក្កកម្មនោះមុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬមុនកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំដែលបានអះអាងក្នុងករណីដែលប្រកាសនីយបត្រតក្កកម្មបានផ្តល់រួចហើយ និងបានផ្តល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ យោងតាមចំណុចនេះសិទ្ធិ របស់អ្នកប្រើប្រាស់មុនអាចផ្ទេរបានជាមួយតែសហគ្រាស ឬក្រុមហ៊ុន ឬមួយផ្នែកនៃសហគ្រាសឬក្រុមហ៊ុនដែលបានប្រើប្រាស់ ឬបានរៀបចំការប្រើប្រាស់តក្កកម្ម នោះរួចហើយ។[58]

**១.២.២. រយៈពេលនៃការការពារ**

ប្រកាសនីយបត្រតក្កកម្ម មានសុពលភាពរយៈពេល ២០(ម្ភៃ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃការស្នើសុំប្រកាសនីយបត្រតក្កកម្មលុះត្រាតែបានបំពេញតាមលក្ខខណ្ឌដូចមានខាងក្រោមនេះ៖

ការបង់កម្រៃប្រចាំឆ្នាំ ត្រូវបង់ជាមុនជូនមន្ត្រីកាន់កាប់បញ្ជីសម្រាប់រយៈពេល ១(មួយ) ឆ្នាំម្តង។ ដោយគិតចាប់ពីពេល ១(មួយ)ឆ្នាំ ក្រោយកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ដើម្បីរក្សាសុពលភាពនៃប្រកាសនីយបត្រតក្កកម្ម ឬសំណុំលិខិតស្នើសុំនៃប្រកាសនីយបត្រតក្កកម្មនោះ។ ការយឺតយ៉ាវក្នុងការបង់កម្រៃប្រចាំឆ្នាំត្រូវបានអនុញ្ញាតយ៉ាងយូរ ៦(ប្រាំមួយ)ខែ ដោយមានការបង់កម្រៃបន្ថែមលើការយឺតយ៉ាវនេះតាមការកំណត់ដូចមានចែងក្នុងមាត្រា១៣០ (បទបញ្ញានិងសេចក្តីណែនាំរដ្ឋបាល) នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។ ប្រសិនបើមិនបានបង់កម្រៃប្រចាំឆ្នាំទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រានេះសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មនឹងត្រូវចាត់ទុកថាបានដកយកទៅវិញ ឬប្រកាសនីយបត្រតក្កកម្មត្រូវអស់សុពលភាព។[59]

---

[58] មាត្រា៤៣ មាត្រា៤៤, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[59] មាត្រា៤៥ មាត្រា៤៦, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

### ១.២.៣. ការផ្សព្វផ្សាយជាសាធារណៈ

ការផ្សព្វផ្សាយជាសាធារណៈ ក៏ជាផ្នែកមួយមានសារៈសំខាន់ផងដែរក្នុងការជួយជំរុញស្នាដៃបង្កើតថ្មីរបស់តក្កករដើម្បីឲ្យមនុស្សទូទៅគ្រប់មជ្ឈដ្ឋានបានស្គាល់បានដឹងបានលឺអំពីតក្កកម្មនោះ។ បុគ្គលទាំងឡាយ ដែលមានប្រយោជន៍ពាក់ព័ន្ធទៅនឹងតក្កកម្មនោះអាចដាក់ពាក្យប្ដឹងជំទាស់ពីការប្រគល់នូវប្រកាសនីយបត្រតក្កកម្មនេះបាន។[60]

- គោលបំណងនៃការផ្សព្វផ្សាយជាសាធារណៈ
  - លើកទឹកចិត្តដល់តក្កករក្នុងការបង្កើតរបកគំហើញថ្មីៗ
  - លើកទឹកចិត្តចំពោះការច្នៃប្រឌិត ការស្រាវជ្រាវ ការអភិវឌ្ឍន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
  - អាចទទួលបានកម្រៃ និងការឧបត្ថម្ភនានា
  - ទទួលបាននូវការកោតសរសើ មានកេរ្តិ៍ឈ្មោះ
  - ប្រទេសជាតិមានមុខមាត់លើឆាកអន្តរជាតិ និងការអភិវឌ្ឍន៍
  - បណ្ដុះគោលគំនិតដល់យុវជនជំនាន់ក្រោយក្នុងការស្រាវជ្រាវ
  - បានដឹងលឺដល់បុគ្គលមានកម្រិតជំនាញធម្មតាបានសិក្សាបន្ថែម
  - អាចផ្សព្វផ្សាយដឹងដល់ពាណិជ្ជករក្នុង និងក្រៅស្រុក និងការវិនិយោគ
  - និងសិទ្ធិទទួលបានពីប្រកាសនីយបត្រតក្កកម្មគឺមានលក្ខណៈដាច់ខាត ផ្ដាច់មុខសិទ្ធិ(សេដ្ឋកិច្ច) និងសិទ្ធិ (សីលធម៌) ដែលសិទ្ធិនេះគ្មានអាជ្ញាយុកាលនោះទេ។

### ១.៣. មោឃភាពនៃប្រកាសនីយបត្រតក្កកម្ម

ទោះបីជាប្រកាសនីយបត្រតក្កកម្ម ត្រូវបានគេចាត់ទុកថាមានភាពវ័យចំណាស់ជាងគេនៅក្នុងកម្មសិទ្ធបញ្ញា ព្រមទាំងជាប្រភពសិទ្ធិដ៏សំខាន់មួយក្នុងការធ្វើអាជីវកម្ម ដែលរដ្ឋបានផ្ដល់សិទ្ធិដ៏សំខាន់មួយនេះទៅដល់ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មក៏ដោយ ក៏ភាពជាម្ចាស់នៃសិទ្ធិនេះអាចត្រូវប្រឈមមុខជាមួយនិងការលុបចោល ឬ មោឃភាពផងដែរក្នុងករណីដែលមានបណ្ដឹងអំពីវិការៈមួយចំនួនក្រោយពីទទួលបានសិទ្ធិ នៃប្រកាសនីយបត្រតក្កកម្ម។[61]

យោងតាមមាត្រា៦៥ នៃច្បាប់ស្ដីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម បានចែងយ៉ាងច្បាស់ថាបុគ្គលដែលមានការពាក់ព័ន្ធអាចស្នើសុំទៅកាន់តុលាការមាន

[60] លោក យឹម ឧត្តម, "នីតិកម្មសិទ្ធិបញ្ញា"។

[61] លោក កាន់ សុខប៉ូលីន, នីតិកម្មសិទ្ធិបញ្ញា, "សិទ្ធិអ្នកនិពន្ធ ម៉ាក ប្រកាសនីយបត្រតក្កកម្ម"។

សមត្ថកិច្ចឱ្យទុកជាមោឃៈនូវប្រកាសនីយបត្រតក្កកម្មបាន។[62] ដោយមោឃភាពនៃប្រកាសនីយបត្រតក្កកម្មនេះ បុគ្គលដែលពាក់ព័ន្ធត្រូវបង្ហាញភស្តុតាងទៅកាន់តុលាការថាបុគ្គលជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនោះមិនមែនជាតក្កករ ឬមិនមែនជាអ្នកស្នងរបស់តក្កករ។ ក្នុងន័យនេះគឺចង់សំដៅទៅលើការប្រព្រឹត្តខុសលក្ខខណ្ឌណាមួយរបស់ម្ចាស់តក្កកម្មរួមមាន៖ វាក្យខណ្ឌទី២ និងទី៣ នៃមាត្រា៣ (ដែលចែងអំពីនិយមន័យនៃតក្កកម្ម) មាត្រា៤ (ចែងអំពីតក្កកម្មដែលមិនអាចជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កម្ម) និងមាត្រា៥ រហូតដល់មាត្រា៩ (ចែងអំពីលក្ខខណ្ឌគ្រឹះនៃតក្កកម្ម និងតក្កកម្មដែលត្រូវហាមជាដាច់ខាត)។[63]

កាលបើប្រកាសនីយបត្រតក្កកម្មត្រូវបានលុបចោល ឬមោឃភាពហើយនោះរាល់សំណុំលិខិត និងឯកសារគតិយុត្តិ រួមទាំងសេចក្តីអះអាងទាំងឡាយដែលទាក់ទងទៅនឹងប្រកាសនីយបត្រតក្កកម្មត្រូវបានចាត់ទុកថាមិនបានការនិងត្រូវអស់សុពលភាពចាប់តាំងពីថ្ងៃដែលផ្តល់ប្រកាសនីយបត្រតក្កកម្ម។[64] ទាក់ទងទៅនឹងសេចក្តីសម្រេចជាស្ថាពររបស់តុលាការនេះផងដែរ សមត្ថកិច្ចត្រូវជូនដំណឹងដល់មន្ត្រីកាន់កាប់បញ្ជីដើម្បីធ្វើការកត់ត្រា និងចុះផ្សាយនៃសេចក្តីសម្រេចរបស់តុលាការឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន។[65]

## ផ្នែកទី ២៖ នីតិវិធីនៃការចុះបញ្ជីតក្កកម្មអន្តរជាតិ

### ២.១. បែបបទនៃការចុះបញ្ជីតក្កកម្មអន្តរជាតិ

#### ក. សំណុំលិខិតស្នើសុំជាអន្តរជាតិ

សំណុំលិខិតស្នើសុំអន្តរជាតិដែលត្រូវដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជ ក្នុងតួនាទីនៅការិយាល័យទទួលសំណុំលិខិតស្នើសុំត្រូវធ្វើជាភាសាណាមួយដែលបានកំណត់។ កម្រៃក្នុងការបញ្ជូនឯកសារត្រូវបង់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីតាមការកំណត់ដូចមានចែងក្នុងមាត្រា១៣០ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។[66]

ការិយាល័យទទួលសំណុំលិខិតស្នើសុំ គឺជាការិយាល័យដែលមានសមត្ថភាពទទួលសំណុំលិខិតស្នើសុំចុះបញ្ជីក្រោយនីតិវិធីនៃសន្ធិសញ្ញា PCT ទទួលថវិកាពាក់ព័ន្ធនឹងការចុះបញ្ជី និងត្រួតពិនិត្យលើសំណុំលិខិតស្នើរសុំដែលបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់ PCT ដើម្បីទទួលបានការចុះបញ្ជីជាអន្តរជាតិ។[67]

[62] មាត្រា៦៥, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។
[63] មាត្រា៦៦, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។
[64] មាត្រា៦៧, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។
[65] មាត្រា៦៨, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។
[66] មាត្រា៨១, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។
[67] មាត្រា១០, សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ។

ដោយយោងទៅតាមវិធាន ១៩.១(ខ) នៃបទប្បញ្ញត្តិរបស់សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម រដ្ឋមន្ត្រីអាចចុះកិច្ចព្រមព្រៀងបាន ដែលតាមរយៈនោះអង្គការអន្តររដ្ឋាភិបាល ឬការិយាល័យជាតិនៃរដ្ឋដែលជាសមាជិកសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ត្រូវអនុវត្តតួនាទីជាការិយាល័យទទួលសំណុំលិខិតស្នើសុំជំនួសនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី សម្រាប់អ្នកដាក់ពាក្យសុំជាជនដែលមានទីលំនៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនដែលមានសញ្ជាតិខ្មែរ។[68]

➢ ការិយាល័យទទួលសំណុំលិខិតស្នើសុំគឺអាចជា៖
  - ការិយាល័យចុះបញ្ជីជាតិ នៃប្រទេសហត្ថលេខី
  - ប្រទេសហត្ថលេខីមួយនៃសន្ធិសញ្ញា PCT បានព្រមព្រៀងជាមួយនឹងអង្គការអន្តរជាតិ រដ្ឋាភិបាលមួយថា ការិយាល័យចុះបញ្ជីជាតិរបស់ខ្លួនគឺជាការិយាល័យទទួលជំនួសរដ្ឋហត្ថលេខី ឬអង្គការអន្តររដ្ឋាភិបាលដែលស្នើសុំនោះ
  - ការិយាល័យអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។[69]

❖ ការិយាល័យទទួលសំណុំលិខិតស្នើសុំត្រូវពិនិត្យមើលចំណុចពីរសំខាន់គឺ ៖

➢ ការិយាល័យទទួលត្រូវកាលបរិច្ឆេទនៃការសុំចុះបញ្ជីលើសំណុំលិខិតស្នើសុំអន្តរជាតិនៅពេលសំណុំលិខិតនេះបានបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖
  - អ្នកដាក់ពាក្យ មានអាស័យដ្ឋាន ឬមានសញ្ញាតិនៃប្រទេសដែលជាសមាជិកសន្ធិសញ្ញា PCT
  - សំណុំលិខិតស្នើរសុំអន្តរជាតិត្រូវមានភាសាដែលបានកំណត់
  - សំណុំលិខិតស្នើរសុំអន្តរជាតិ ត្រូវមានយ៉ាងហោចណាស់ នូវធាតុទាំងឡាយដូចជាការបញ្ជាក់ ថាសំណុំលិខិតស្នើរសុំ នេះត្រូវបានគ្រោងទុកជា សំណុំលិខិតស្នើរសុំអន្តរជាតិមានការជ្រើសរើសយ៉ាងហោចណាស់ក៏មាន រដ្ឋហត្ថលេខីមួយ មានឈ្មោះរបស់អ្នកដាក់ពាក្យសុំយ៉ាតិចម្នាក់ មានផ្នែកមួយនៃសេចក្តីអត្ថាធិប្បាយ និងមានផ្នែកមួយនៃសេចក្តីអះអាង។[70]

➢ ការិយាល័យទទួលត្រូវពិនិត្យលើភាពខ្វះខាតចន្លោះលើសំណុំលិខិតស្នើសុំអន្តរជាតិដូចខាងក្រោម៖
  - មិនមានចុះហត្ថលេខា
  - មិនមានការបញ្ជាក់ដូចបានកំណត់ពាក់ព័ន្ធអ្នកដាក់ពាក្យសុំ
  - មិនមានចំណងជើងតក្កកម្ម

---

[68] មាត្រា៨០, ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[69] មាត្រា១៩, នៃវិធានស្ថិតក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ។

[70] មាត្រា១១(១), សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ។

- មិនមានខ្លឹមសារសង្ខេប
- មិនបានបំពេញតាមការកំណត់ក្នុងបទបញ្ជា។[71]

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ត្រូវអនុវត្តតួនាទីជាការិយាល័យទទួលសំណុំលិខិតស្នើសុំចំពោះសំណុំលិខិតស្នើសុំអន្តរជាតិដែលបានដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីដោយជនដែលមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនដែលមានសញ្ជាតិខ្មែរក្នុងគោលបំណងទទួលបានប្រកាសនីយបត្រតក្កកម្ម។[72]

សំណុំលិខិតស្នើសុំត្រូវអនុវត្តចំពោះសំណុំលិខិតស្នើសុំជាតិ និងតំបន់ចំពោះប្រកាសនីយបត្រតក្កកម្មសម្រាប់តក្កកម្ម និងប្រកាសនីយបត្រតក្កកម្មសម្រាប់បន្ថែមដែលបានដាក់នៅ ឬសម្រាប់ការិយាល័យនៃភាគីហត្ថលេខីហើយដែលជា៖

- ប្រភេទសំណុំលិខិតស្នើសុំដែលអនុញ្ញាតដើម្បីដាក់ជាសំណុំលិខិតស្នើសុំអន្តរជាតិ ក្នុងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម
- សំណុំលិខិតស្នើសុំបំបែកនៃប្រភេទសំណុំលិខិតស្នើសុំ ដូចមានចែងក្នុងចំណុចខាងលើ ឬដូចមានចែងក្នុងមាត្រា៤ ចំណុច (ឆ) នៃអនុសញ្ញាទីក្រុងប៉ារីស ដែលមានខ្លឹមសារថា៖[73]
  - ប្រសិនបើការត្រួតពិនិត្យបង្ហាញថាសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម មានតក្កកម្មច្រើនជាងមួយ នោះអ្នកដាក់ពាក្យស្នើសុំអាចបំបែកសំណុំលិខិតស្នើសុំទៅជា សំណុំលិខិតស្នើសុំបំបែក ហើយអ្នកដាក់ពាក្យស្នើសុំអាចរក្សាកាលបរិច្ឆេទ ដូចកាលបរិច្ឆេទសំណុំលិខិតស្នើសុំដំបូង ហើយប្រសិនបើមានក៏អាចរក្សាផលប្រយោជន៍នៃសិទ្ធិ អាទិភាពបានផងដែរ។
  - តាមគំនិតផ្តួចផ្តើមរបស់ខ្លួនអ្នកដាក់ពាក្យស្នើសុំអាចបំបែកសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម នឹងអាចរក្សាកាលបរិច្ឆេទនៃសំណុំលិខិតស្នើសុំបំបែកនីមួយៗដូចកាលបរិច្ឆេទសំណុំលិខិតស្នើសុំដំបូងហើយប្រសិនបើមានក៏អាចរក្សាផលប្រយោជន៍នៃសិទ្ធិអាទិភាពបានផងដែរ។
  - ប្រទេសនីមួយៗនៃសហភាពមានសិទ្ធិកំណត់លក្ខខណ្ឌ នៃការអនុញ្ញាតឱ្យបំបែកសំណុំលិខិតស្នើសុំបាន។[74]
- ទម្រង់ ឬមាតិកានៃសំណុំលិខិតស្នើសុំ គ្មានភាគីហត្ថលេខីណាត្រូវតម្រូវឱ្យបំពេញលក្ខខណ្ឌតម្រូវណាមួយពាក់ព័ន្ធនឹងទម្រង់ ឬមាតិកានៃសំណុំលិខិតស្នើសុំផ្សេងពី ឬបន្ថែមទៅលើ៖

---

[71] មាត្រា១៤, សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ។

[72] មាត្រា៧៩, ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

[73] មាត្រា៣,សន្ធិសញ្ញាស្តីពី ច្បាប់ប្រកាសនីយបត្រតក្កកម្ម។

[74] មាត្រា៤ (ឆ), អនុសញ្ញាទីក្រុងប៉ារីស ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម, ២០.មីនា.១៨៨៣។

- លក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងទម្រង់ ឬមាតិកាដែលមានចែងចំពោះសំណុំលិខិតស្នើសុំអន្តរជាតិក្នុងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម
- លក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងទម្រង់ ឬមាតិកាដែលតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម អាចទាមទារដោយការិយាល័យនៃ ឬការិយាល័យតំណាងរដ្ឋជាភាគីណាមួយនៃសន្ធិសញ្ញានេះនៅពេលចាប់ផ្តើមដំណើរ ឬចាប់ផ្តើមត្រួតពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ។

➢ **ទម្រង់ពាក្យសុំ**

- ភាគីហត្ថលេខីមួយអាចតម្រូវឱ្យ មាតិកានៃសំណុំលិខិតស្នើសុំដែលដូចនឹងមាតិកានៃពាក្យសុំនៃសំណុំលិខិតស្នើសុំអន្តរជាតិតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម បង្ហាញក្នុងទម្រង់ពាក្យសុំដែលកំណត់ដោយភាគីហត្ថលេខីនោះ។ភាគីហត្ថលេខីក៏អាចតម្រូវឱ្យមានក្នុងទម្រង់ពាក្យសុំនោះនូវមាតិកាផ្សេងទៀត។

➢ **ការបកប្រែ**

- ភាគីហត្ថលេខីអាចតម្រូវឱ្យមានការបកប្រែផ្នែកណាមួយនៃសំណុំលិខិតស្នើសុំ ដែលមិនមែនជាភាសាដែលទទួលយកដោយការិយាល័យចុះបញ្ជី។ ភាគីហត្ថលេខីក៏អាចតម្រូវផងដែរឱ្យបកប្រែផ្នែកនៃសំណុំលិខិតស្នើសុំពីភាសាដែល មិនទទួលយកដោយការិយាល័យទៅជាភាសាផ្សេងទៀតដែលទទួលយកដោយការិយាល័យ ដូចមានកំណត់ក្នុងបទបញ្ជា។

➢ **កម្រៃ**

- ភាគីហត្ថលេខីអាចតម្រូវឱ្យបង់កម្រៃចំពោះសំណុំលិខិតស្នើសុំ។ ភាគីហត្ថលេខីអាចអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ទាក់ទងនឹងការបង់កម្រៃសំណុំលិខិតស្នើសុំ។

➢ **ឯកសារអាទិភាព**

- នៅពេលដែលមានការអះអាងអាទិភាពនៃសំណុំលិខិតស្នើសុំពីមុន ភាគីហត្ថលេខីអាចតម្រូវឱ្យដាក់ច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំ ស្នើសុំពីមុន និងការបកប្រែក្នុងករណីសំណុំលិខិតស្នើសុំពីមុនមិនធ្វើឡើងក្នុងភាសាដែលទទួលយកដោយការិយាល័យ ដោយអនុលោមតាមលក្ខខណ្ឌតម្រូវដែលកំណត់ក្នុងបទបញ្ជា។

➢ **ភស្តុតាង**

- ភាគីហត្ថលេខីអាចតម្រូវឱ្យភស្តុតាងដែលពាក់ព័ន្ធនឹងបញ្ហាណាមួយ ក្នុងសេចក្តីប្រកាសអាទិភាព ឬការបកប្រែណាមួយ ដាក់នៅការិយាល័យនៃភាគីហត្ថលេខី ក្នុងពេលដំណើរការសំណុំលិខិតស្នើសុំ តែក្នុងករណីដែលការិយាល័យអាចសង្ស័យដោយសមហេតុសមផលពីភាពពិតប្រាកដនៃបញ្ហានោះ ឬពីភាពត្រឹមត្រូវនៃការបកប្រែនោះ។

➢ **ការជូនដំណឹង**

- នៅពេលដែលមិនបានបំពេញល័ក្ខខ័ណ្ឌតម្រូវមួយ ឬច្រើនដែលត្រូវអនុវត្តដោយភាគីហត្ថលេខី ការិយាល័យត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំដោយផ្តល់ឱកាស ឱ្យមកបំពេញលក្ខខណ្ឌតម្រូវ និងដើម្បីធ្វើការសង្កេតតាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ញា។

➢ **ការមិនបំពេញលក្ខខណ្ឌតម្រូវ**

- នៅពេលដែលមិនបានបំពេញលក្ខខណ្ឌតម្រូវមួយ ឬច្រើនដែលត្រូវអនុវត្តដោយភាគីហត្ថលេខីតាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ញា ភាគីហត្ថលេខីអាចអនុវត្តទណ្ឌកម្មដូចមានចែងក្នុងច្បាប់របស់ខ្លួន។
- នៅពេលដែលមិនបានបំពេញលក្ខខណ្ឌតម្រូវណាមួយ ដែលត្រូវអនុវត្តដោយភាគីហត្ថលេខីចំពោះការអះអាងអាទិភាពតាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ញា ការអះអាងអាទិភាពអាចចាត់ទុកថាមិនបានធ្វើឡើយ។[75]

**ខ. កាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំជាអន្តរជាតិ**

សម្រាប់ការដាក់ពាក្យសុំក្នុងប្រទេសដទៃបុគ្គល ឬអ្នកទទួលសិទ្ធិដែលដាក់ពាក្យសុំចុះបញ្ជីយ៉ាងត្រឹមត្រូវនូវប្រកាសនីយបត្រតក្កកម្មនៅក្នុងប្រទេសណាមួយនៃសហភាពត្រូវទទួលបាននូវសិទ្ធិអាទិភាពក្នុងអំឡុងពេលកំណត់ដូចមានចែងក្នុងអនុសញ្ញាទីក្រុងប៉ារីស។ ការដាក់ពាក្យសុំដែលសមមូលនឹងការដាក់ពាក្យសុំធម្មតាថ្នាក់ជាតិ ក្រោមច្បាប់ជាតិនៃប្រទេសក្នុងសហភាព ឬក្រោមអនុសញ្ញាទ្វេភាគី ឬពហុភាគីដែលបង្កើតឡើងដោយប្រទេសសមាជិកទាំងឡាយនៃសហភាពត្រូវទទួលបានសិទ្ធិអាទិភាព។ ការដាក់ពាក្យសុំធម្មតាថ្នាក់ជាតិមានន័យថា ការដាក់ពាក្យសុំណាមួយដែលមានលក្ខណៈត្រឹមត្រូវដែលបង្កើតបានកាលបរិច្ឆេទចំពោះការដាក់ពាក្យដែលបានធ្វើក្នុងប្រទេសដែលពាក់ព័ន្ធទោះបីបើការដាក់ពាក្យស្នើសុំនោះមានលទ្ធផលយ៉ាងណាក៏ដោយ។

រយៈពេលអាទិភាពត្រូវមានរយៈពេល១២(ដប់ពីរ)ខែ ចំពោះប្រកាសនីយបត្រតក្កកម្មរយៈពេលទាំងនេះត្រូវរាប់ចាប់ផ្តើមពីកាលបរិច្ឆេទនៃការដាក់សំណុំលិខិតស្នើសុំដំបូង។ ថ្ងៃដាក់ពាក្យសុំមិនត្រូវរាប់បញ្ចូលក្នុងរយៈ

[75] មាត្រា៦, សន្ធិសញ្ញាស្តីពីច្បាប់ប្រកាសនីយបត្រតក្កកម្ម។

ពេលនោះទេ។ ប្រសិនបើថ្ងៃចុងក្រោយនៃរយៈពេលនេះជាថ្ងៃឈប់សម្រាកផ្លូវការ ឬជាថ្ងៃដែលការិយាល័យបិទមិនទទួលការដាក់ពាក្យសំណុំលិខិតស្នើសុំ នៅក្នុងប្រទេសសុំការពារ រយៈពេលនេះត្រូវពន្យារហូតដល់ថ្ងៃធ្វើការបន្ទាប់។[76]

(១). **ធាតុនៃសំណុំលិខិតស្នើសុំ**

ក. ភាគីហត្ថលេខី ត្រូវចែងថាកាលបរិច្ឆេទនៃការសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំត្រូវជាកាលបរិច្ឆេទដែលការិយាល័យទទួលបានធាតុទាំងអស់ដូចខាងក្រោមដែលបានដាក់ជាជម្រើសរបស់អ្នកដាក់ពាក្យសុំ ក្នុងទម្រង់ក្រដាស ឬមធ្យោបាយផ្សេងដែលអនុញ្ញាតដោយការិយាល័យសម្រាប់គោលបំណងនៃការបរិច្ឆេទនៃការសុំចុះបញ្ជី៖

- ការបញ្ជាក់យ៉ាងច្បាស់លាស់ ឬគ្រប់គ្រាន់ដែលមានអានុភាពបញ្ជាក់ថាធាតុទាំងឡាយត្រូវមានក្នុងសំណុំលិខិតស្នើសុំ
- ការបញ្ជាក់អំពីអត្តសញ្ញាណនៃអ្នកដាក់ពាក្យសុំ ឬការបញ្ជាក់ដែលអនុញ្ញាតឱ្យការិយាល័យអាចទាក់ទងជាមួយអ្នកដាក់ពាក្យសុំបាន
- ផ្នែកមួយនៃសំណុំលិខិតស្នើសុំដែលនៅលើផ្នែកនោះមានបញ្ជាក់នូវសេចក្ដីអធិប្បាយ។

ខ. ជាគោលបំណងនៃការបរិច្ឆេទការសុំចុះបញ្ជី ភាគីហត្ថលេខីអាចទទួលយកគំនូសបង្ហាញ។

គ. ជាគោលបំណង នៃការបរិច្ឆេទសុំចុះបញ្ជីភាគីហត្ថលេខីអាចតម្រូវឱ្យផ្ដល់ទាំងពត៌មានអំពីអត្តសញ្ញាណនៃអ្នកដាក់ពាក្យសុំ និងព័តមានដែលអាចអនុញ្ញាតឱ្យការិយាល័យអាចទាក់ទងជាមួយអ្នកដាក់ពាក្យស្នើសុំបាន ឬភាគីហត្ថលេខីអាចទទួលយកភស្តុតាងអំពីអត្តសញ្ញាណនៃអ្នកដាក់ពាក្យសុំ ឬដែលអាចអនុញ្ញាតឱ្យការិយាល័យ អាចទាក់ទងជាមួយអ្នកដាក់ពាក្យសុំបាន។

(២). **ភាសា**

ក. ភាគីហត្ថលេខីអាចតម្រូវឱ្យមានការបញ្ជាក់ធ្វើជាភាសាមួយដែលទទួលយកដោយការិយាល័យ។

ខ. ផ្នែកមួយនៃសំណុំលិខិតស្នើសុំ ដែលនៅលើផ្នែកនោះមានបញ្ជាក់នូវសេចក្ដីអធិប្បាយអាចដាក់ជាភាសាណាមួយ ជាគោលបំណងនៃការបរិច្ឆេទការសុំចុះបញ្ជី។

ភាសាដែលប្រើប្រាស់ជាផ្លូវការសម្រាប់សំណុំលិខិតស្នើសុំអន្តរជាតិត្រូវតែជា៖

ភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង អាល្លឺម៉ង់ ជប៉ុន កូរ៉េ ព័រទុយហ្គាល អេស្ប៉ាញ ឬភាសាដែលទទួលស្គាល់ដោយការិយាល័យទទួល។ ករណីដែលសំណុំលិខិតស្នើសុំអន្តរជាតិ មិនបានប្រើប្រាស់ភាសា ដែលបានកំណត់

[76] មាត្រា៤, ក,ខ,គ, អនុសញ្ញាទីក្រុងប៉ារីស ស្ដីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម, ២០.មីនា.១៨៨៣។

តាមលក្ខខណ្ឌខាងលើ អ្នកដាក់ពាក្យសុំត្រូវតែបកប្រែសំណុំលិខិតស្នើសុំអន្តរជាតិជាភាសាដែលបានកំណត់ក្នុងរយៈពេល ០១(មួយ)ខែ បន្ទាប់ពីការិយាល័យទទួលបានទទួលនូវសំណុំលិខិតស្នើសុំអន្តរជាតិនោះ។ប្រសិនមិនបកប្រែទាន់ពេលវេលាកំណត់ទេនោះ ការិយាល័យទទួលនឹងប្រកាសថាសំណុំលិខិតស្នើសុំអន្តរជាតិនោះនឹងដកចេញពីនីតិវិធីចុះបញ្ជីតាមសន្ធិសញ្ញា PCT ។

(៣). **ការជូនដំណឹង**

នៅពេលដែលសំណុំលិខិតស្នើសុំមិនអនុលោមតាមលក្ខខ័ណ្ឌតម្រូវមួយ ឬច្រើនដែលត្រូវអនុវត្តដោយការិយាល័យ ការិយាល័យត្រូវផ្តល់ដំណឹងដល់អ្នកដាក់ពាក្យសុំភ្លាមតាមតែអាចធ្វើទៅបាន ដោយផ្តល់ឱកាសឱ្យបំពេញលក្ខខណ្ឌតម្រូវណាមួយនេះ និងដើម្បីធ្វើការសង្កេតតាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា។

(៤). **ការជូនដំណឹងពាក់ព័ន្ធនឹងការខ្វះផ្នែកណាមួយនៃសេចក្តីអធិប្បាយ ឬគំនូសបង្ហាញ**

ពេលចុះកាលបរិច្ឆេទនៃការសុំចុះបញ្ជី នៅពេលដែលការិយាល័យរកឃើញថាផ្នែកមួយ នៃសេចក្តីអធិប្បាយបានខ្វះក្នុងសំណុំលិខិតស្នើសុំ ឬសំណុំលិខិតស្នើសុំនោះយោងទៅគំនូសបង្ហាញដែលបានខ្វះក្នុងសំណុំលិខិតស្នើសុំ ការិយាល័យត្រូវជូនដំណឹងភ្លាមដល់អ្នកដាក់ពាក្យសុំ។

(៥). **កាលបរិច្ឆេទនៃការសុំចុះបញ្ជី នៅពេលដែលបានដាក់ផ្នែកនៃសេចក្តីអធិប្បាយ ឬគំនូសបង្ហាញដែលខ្វះ**

ក. នៅពេលផ្នែកណាដែលខ្វះនៃសេចក្តីអធិប្បាយ ឬគំនូសបង្ហាញបានដាក់នៅការិយាល័យតាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា ផ្នែកនេះនៃសេចក្តីអធិប្បាយ ឬគំនូសបង្ហាញត្រូវបញ្ចូលក្នុងសំណុំលិខិតស្នើសុំ។ កាលបរិច្ឆេទនៃការសុំចុះបញ្ជីត្រូវជាកាលបរិច្ឆេទដែលការិយាល័យទទួលបានផ្នែកនេះ នៃសេចក្តីអធិប្បាយ ឬគំនូសបង្ហាញ ឬត្រូវជាកាលបរិច្ឆេទនៃការបំពេញរាល់លក្ខខណ្ឌតម្រូវទាំងអស់ដែលត្រូវអនុវត្តដោយភាគីហត្ថលេខីដោយយកកាលបរិច្ឆេទណាដែលយូរជាងគេ។

ខ. នៅពេលដែលផ្នែកដែលខ្វះនៃសេចក្តីអធិប្បាយ ឬគំនូសបង្ហាញបានដាក់ដើម្បីកែតម្រូវការលុបចោលពីសំណុំលិខិតស្នើសុំតាមកាលបរិច្ឆេទត្រូវបានទទួលពីដំបូងដោយការិយាល័យ ដែលអះអាងអាទិភាពនៃសំណុំលិខិតស្នើសុំមុន តាមសំណើរបស់អ្នកដាក់ពាក្យសុំដែលបានដាក់តាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា និងលើកលែងតែលក្ខខណ្ឌតម្រូវដែលបានកំណត់ក្នុងបទបញ្ជាកាលបរិច្ឆេទនៃការសុំចុះបញ្ជីត្រូវជាកាលបរិច្ឆេទនៃការបំពេញរាល់លក្ខខណ្ឌតម្រូវទាំងអស់ដែលត្រូវអនុវត្តដោយភាគីហត្ថលេខី។[77]

[77] មាត្រា៥, សន្ធិសញ្ញាស្តីពីច្បាប់ប្រកាសនីយបត្រតក្កកម្ម។

**គ. ការពិនិត្យជំហានដំបូង**

ការពិនិត្យជំហានដំបូងអន្តរជាតិគឺជានីតិវិធីដែលអ្នកដាក់ពាក្យសុំអាចជ្រើសរើស និងដាក់ពាក្យទាមទារដាច់ដោយឡែកពីសំណុំលិខិតស្នើសុំអន្តរជាតិទៅអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិ។ ការិយាល័យទទួលត្រូវតែជ្រើសតាំងអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិ ដែលអាចជាការិយាល័យជាតិនៃប្រទេសហត្ថលេខី ឬការិយាល័យថ្នាក់តំបន់ដែលមានសមត្ថភាពក្នុងការអនុវត្តន៍ការពិនិត្យជំហានដំបូងអន្តរជាតិជាមុនសិន។ ក្នុងករណីដែលការិយាល័យទទួលមានអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិច្រើនជាងមួយ អ្នកដាក់ពាក្យសុំអាចជ្រើសតាំងអាជ្ញាធរមួយក្នុងចំណោមអាជ្ញាធរទាំងនោះ។[78] កម្មវត្ថុនៃការពិនិត្យជំហានដំបូងអន្តរជាតិ គឺ ចងក្រងយោបល់ជាជំហានដំបូងនឹងឱ្យយោបល់លើលក្ខណៈវិនិច្ឆ័យ ធាតុតក្កកម្មដែលស្នើសុំនោះមានភាពថ្មី មានជំហានរកឃើញថ្មី និងអាចយកមកអនុវត្តក្នុងឧស្សាហកម្មដែរ ឬទេដើម្បីពិនិត្យឱ្យដឹងថាតក្កម្មនោះដែលបានអះអាងអាចទទួលបានប្រកាសនីយបត្រតក្កកម្មបានដែរឬទេ។ អ្នកដាក់ពាក្យសុំអាចពិចារណាជ្រើសរើសនីតិវិធីពិនិត្យជំហានដំបូងជាអន្តរជាតិ ព្រោះនីតិវិធីនេះនឹងនាំឱ្យអ្នកដាក់ពាក្យស្នើសុំ ដឹងជាមុនដើម្បីធ្វើការសម្រួលសេចក្តីអត្ថាធិប្បាយ ការអះអាង និងគំនូសបង្ហាញនៃសំណុំឯកសារស្នើសុំរបស់ខ្លួន ជៀសវាងការជំទាស់ក្នុងការចុះបញ្ជីនៅការិយាល័យជាតិ ឬនាំឱ្យខូចខាតពេលវេលានៅក្នុងដំណាក់ការជាតិ។[79]

ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិត្រូវដាក់ទៅអាជ្ញាធរត្រួតពិនិត្យហានដំបូងអន្តរជាតិដែលមានសមត្ថភាពក្នុងរយៈពេល ០៣ (បី)ខែ គិតចាប់ពីថ្ងៃបញ្ជូនរបាយការណ៍ស្រាវជ្រាវអន្តរជាតិ និងផ្តល់យោបល់ជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ឬក្នុងរយៈពេល ២២(ម្ភៃពីរ)ខែ គិតចាប់ពីការបរិច្ឆេទទាមទារអាទិភាព។

- ដើម្បីអាចដាក់ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិបានលុះត្រាតែគោរពតាមលក្ខខណ្ឌចំនួនពីរដូចខាងក្រោមៈ
  - អ្នកដាក់ពាក្យសុំត្រូវមានអាស័យដ្ឋាន ឬសញ្ញាតិនៃប្រទេសសមាជិកដែលព្រមទទួលការអនុវត្តន៍ក្នុងជំពូក២ នៃសន្ធិសញ្ញា PCT។
  - សំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវតែដាក់នៅការិយាល័យទទួលនៃប្រទេសសមាជិកដែលព្រមទទួលការអនុវត្តន៍ក្នុងជំពូកទី២ នៃសន្ធិសញ្ញា PCT ។[80]

បន្ទាប់ពីបញ្ចប់ដំណាក់កាលនីតិវិធីថ្នាក់អន្តរជាតិ នីតិវិធីនេះនឹងត្រូវបន្តពិនិត្យនៅកម្រិតជាតិដែលជាដំណាក់កាលបញ្ចប់នៃនីតិវិធីចុះបញ្ជីប្រកាសនីយបត្រតក្កកម្មតាម PCT ។ ទោះបីយ៉ាងណាការពិនិត្យថ្នាក់ជាតិ

[78] មាត្រា៣១(៤),សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ។
[79] មាត្រា៣៩(១), សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ។
[80] មាត្រា៣១(២)(ក), សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ។

នឹងចាប់ផ្ដើមហើយអ្នកដាក់ពាក្យសុំ ត្រូវអនុវត្តសកម្មភាពមួយចំនួនដែលបានកំណត់ឱ្យបានមុនការផុតកំណត់នៃកាលបរិច្ឆេទ។[81]

គួរបញ្ជាក់ផងដែរថា អ្នកដាក់ពាក្យសុំត្រូវមានទំនួលខុសត្រូវខ្លួនឯងក្នុងការចាប់ផ្ដើមការពិនិត្យថ្នាក់ជាតិឱ្យបានទាន់ពេលកំណត់របស់ច្បាប់។ រយៈពេលដើម្បីទទួលការពិនិត្យកម្រិតជាតិត្រូវចាប់ផ្ដើមពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ មិនឱ្យយឺតជាងការផុតកំណត់នៃរយៈពេល ០៣ (បី) ខែគិតចាប់ពីកាលបរិច្ឆេទអាទិភាព។

## ២.២. សិទ្ធិ និងកិច្ចការពារទទួលបានពីការចុះបញ្ជីជាអន្តរជាតិ

សិទ្ធិទទួលបានពីប្រកាសនីយបត្រតក្កកម្មជាអន្តរជាតិ គឺមានលក្ខណៈដាច់ខាត ផ្ដាច់មុខសិទ្ធិ (សេដ្ឋកិច្ច) និងសិទ្ធិ(សីលធម៌)ដែលសិទ្ធិនេះគ្មានអាជ្ញាយុកាលនោះទេ ហើយតក្កករអាចទាញផលប្រយោជន៍បានតាមរយៈស្នាដៃរបស់ខ្លួនដូចជាអាចផ្សព្វផ្សាយដឹងដល់ពាណិជ្ជករក្នុង និងក្រៅស្រុក និងការវិនិយោគ ទទួលបានការលើកទឹកចិត្តចំពោះការច្នៃប្រឌិត ការស្រាវជ្រាវ ការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការផ្សព្វផ្សាយជាសាធារណៈ ឬអាចទាញផលប្រយោជន៍ដូចជាការធ្វើអាជីវកម្មលើតក្កកម្មនោះនៅក្នុងរង្វង់សមាជិកសន្ធិសញ្ញា PCT ដែលតក្កករបានដាក់ស្នើសុំប្រកាសនីយបត្រតក្កកម្មជាអន្តរជាតិ ដែលជាផ្នែកមួយមានសារៈសំខាន់ក្នុងការជួយជំរុញស្នាដៃបង្កើតថ្មីរបស់តក្កករដើម្បីឱ្យមនុស្សទូទៅគ្រប់មជ្ឈដ្ឋានបានស្គាល់ បានដឹងលឺអំពីតក្កកម្មនោះ។ បន្ទាប់ពីទទួលបានប្រកាសនីយបត្រតក្កកម្មជាអន្តរជាតិ តក្កកម្មនោះគឺទទួលបានការការពាររយៈពេល២០(ម្ភៃ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃការស្នើសុំប្រកាសនីយបត្រតក្កកម្ម លុះត្រាតែបានបំពេញតាមលក្ខខណ្ឌដូចមានខាងក្រោមនេះ៖

ការបង់កម្រៃប្រចាំឆ្នាំ ត្រូវបង់ជាមុនជូនមន្ត្រីកាន់កាប់បញ្ជីសម្រាប់រយៈពេល ១(មួយ)ឆ្នាំម្ដង។ ដោយគិតចាប់ពីពេល ១(មួយ)ឆ្នាំ ក្រោយកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ដើម្បីរក្សាសុពលភាពនៃប្រកាសនីយបត្រតក្កកម្ម ឬសំណុំលិខិតស្នើសុំនៃប្រកាសនីយបត្រតក្កកម្មនោះ ។

ប្រកាសនីយបត្រតក្កកម្មជាអន្តរជាតិមានវិសាលភាពគ្រប់ប្រទេសដែលជាសមាជិកសន្ធិសញ្ញា PCT ហើយម្ចាស់ប្រកាសនីយបត្រអន្តរជាតិ អាចប្រើប្រាស់ និងទាញផលប្រយោជន៍បានពីប្រទេសដែលជាសមាជិកនៃសន្ធិសញ្ញាដែលខ្លួនចង់ទទួលបានការការពារពីប្រទេសនោះ។

ប្រកាសនីយបត្រតក្កកម្មជាអន្តរជាតិ គឺមិនស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋនោះទេ ហើយរដ្ឋក៏មិនអាចធ្វើអាជីវកម្មបានផងដែរ។

[81] មាត្រា២២, សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ។

ប្រកាសនីយបត្រតក្កកម្មជាអន្តរជាតិ គឺតក្កកម្មដែលរកឃើញមិនស្ថិតក្នុងប្រទេសដែលបានដាក់ពាក្យស្នើសុំ ហើយបែបបទនៃការដាក់សុំគឺមានច្រើនដំណាក់កាល និងត្រូវភ្ជាប់មកជាមួយនូវឯកសារចម្លងនៃលិខិតឆ្លើយឆ្លងដែលពាក់ព័ន្ធទៅនឹងលទ្ធផលនៃការស្រាវជ្រាវ ឬលទ្ធផលនៃការពិនិត្យសំណុំលិខិតស្នើសុំជាអន្តរជាតិដែលអ្នកដាក់ពាក្យសុំបានទទួល នឹងភាសាដែលប្រើប្រាស់ជាផ្លូវការសម្រាប់សំណុំលិខិតស្នើសុំអន្តរជាតិត្រូវតែជា៖

ភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង អាល្លឺម៉ង់ ជប៉ុន កូរ៉េ ព័រទុយហ្គាល អេស្ប៉ាញ ឬភាសាដែលទទួលស្គាល់ដោយការិយាល័យទទួល។ ករណីដែលសំណុំលិខិតស្នើសុំអន្តរជាតិ មិនបានប្រើប្រាស់ភាសា ដែលបានកំណត់តាមលក្ខខណ្ឌខាងលើអ្នកដាក់ពាក្យសុំត្រូវតែបកប្រែសំណុំលិខិតស្នើសុំអន្តរជាតិជាភាសាដែលបានកំណត់ក្នុងរយៈពេល ០១ (មួយ) ខែបន្ទាប់ពីការិយាល័យទទួលបានទទួលនូវសំណុំលិខិតស្នើសុំអន្តរជាតិនោះ។ ប្រសិនបើមិនបកប្រែទាន់ពេលវេលាកំណត់នោះទេ ការិយាល័យទទួលនឹងប្រកាសថាសំណុំលិខិតស្នើសុំអន្តរជាតិនោះ នឹងដកចេញពីនីតិវិធីចុះបញ្ជីតាមសន្ធិសញ្ញា PCT ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមស្រាវជ្រាវ និងបកស្រាយប្រធានបទ “លក្ខខណ្ឌគតិយុត្តនៃប្រកាសនីយបត្រតកម្ម និងនីតិវិធីនៃការចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិ” ខាងលើរួចមក យើងសង្កេតឃើញថាដើម្បីទទួលប្រកាសនីយបត្រតក្កកម្មជាតិ និងប្រកាសនីយបត្រតក្កកម្មអន្តរជាតិ សុទ្ធសឹងតែត្រូវធ្វើការស្នើសុំទទួលបានការការពារ ថ្មី ជំហ៊ាននៃការរកឃើញថ្មី និងអាចអនុវត្តបាននៅក្នុងឧស្សាហកម្មបាន។ ហើយទាក់ទងទៅនិងគោលបំណងរបស់ប្រកាសនីយបត្រទាំងពីរប្រភេទនេះ គឺលើកទឹកចិត្តទៅលើការបង្ហាញរាល់តក្កកម្ម ដែលតក្កករបានបង្កើត ដែលទាក់ទងទៅ និងបច្ចេកវិទ្យាថ្មីទំនើបព្រមទាំងការអភិវឌ្ឍនៅអ្វីដែលថ្មីបន្ថែមទៀត។ ដោយយើងសង្កេតឃើញថាប្រកាសនីយបត្រតក្កកម្ម ក៏បានជួយដល់តក្កករក្នុងការទាញយកនូវផលប្រយោជន៍ទាំងផ្នែកសេដ្ឋកិច្ចទីផ្សារឧស្សាហកម្មព្រមទាំងភាពល្បីល្បាញដែលជាផ្នែកមួយជួយទៅដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិផងដែរ។ ជាក់ស្តែងដើម្បីទទួលបាននូវការការពារ ប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ តក្កករត្រូវប្រាកដខ្លួនឯងថាគ្រប់ការរកឃើញថ្មីទាំងឡាយ ដាច់ខាតត្រូវតែស្នើសុំចុះបញ្ជី ហើយដែលជាបែបបទក្នុងការស្នើសុំត្រូវតែមានដូចជាពាក្យសុំ សេចក្តីអធិប្បាយ សេចក្តីអះអាង ខ្លឹមសារសង្ខេប ដើម្បីឱ្យមន្ត្រីកាន់កាប់បញ្ជីត្រួតពិនិត្យ និងបញ្ជាក់ថាតក្កកម្មដែលម្ចាស់សាមីខ្លួនដែលធ្វើការចុះបញ្ជីនោះ គឺត្រឹមត្រូវទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ និងមិនប៉ះពាល់ដល់មនុស្សព្រមទាំងសណ្តាប់សាធារណៈផងដែរ។

បើក្រឡេកទៅមើលកាចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិយើងឃើញថាមានភាពខុសគ្នាបន្តិចបន្តួចផងដែរ។ ដោយបែបបទនៃការស្នើសុំចុះបញ្ជីតក្កកម្មជាតិ គឺតម្រូវអោយមានពាក្យសុំ សេចក្តីអធិប្បាយ សេចក្តីអះអាងខ្លឹមសារសង្ខេបជាអាទិ៍។ ដែលសម្តកិច្ចទទួលបន្ទុកក្នុងការចុះបញ្ជី គឺមាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្មរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដែលមានប្រធានមួយរូបដែលមានតួនាទីដឹកនាំក្នុងការស្នើសុំចុះបញ្ជី គឺជាអ្នកកាន់កាប់បញ្ជី។ រីឯបែបបទនៃការស្នើសុំចុះបញ្ជីតក្កកម្មអន្តរជាតិវិញ គឺតម្រូវអោយមានទម្រង់ពាក្យសុំ ការបកប្រែ កម្រៃ ភស្តុតាង ការជូនដំណឹង ការមិនបំពេញលក្ខខណ្ឌតម្រូវជាដើម។ ដោយតាមរយៈសហប្រតិបត្តការប្រកាសនីយបត្រតក្កកម្ម អ្នកមានសមត្ថកិច្ចចុះបញ្ជីមានសន្និបាតគណៈកម្មាធិការប្រតិបត្តិការិយាល័យអន្តរជាតិ និងគណៈកម្មាធិការសហប្រតិបត្តការបច្ចេកទេសដែលបានបែងចែកនូវតួនាទីដាច់ដោយឡែកពីគ្នាដើម្បីជួយសម្រួល ក៏ដូចជាជួយទៅដល់ការពន្លឿននីតិវិធីឱ្យកាន់តែឆាប់រហ័ស។

សរុបសេចក្តីមកលក្ខខណ្ឌគតិយុត្តនៃប្រកាសនីយបត្រតកម្ម និងនីតិវិធីនៃការចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិសុទ្ធសឹងតែផ្តល់នូវផលប្រយោជន៍ទៅដល់តក្កករតាមរយៈការការពារមិនឱ្យបុគ្គលដទៃមានគំនិត

បំពានបាន។ ជាពិសេស គឺផ្តល់ជាភាពងាយស្រួល និងឆាប់រហ័សក្នុងការទាញយកផលប្រយោជន៍ ឬទាញយកប្រាក់ចំណេញជាដើម ដែលជាផ្នែកមួយធ្វើអោយសេដ្ឋកិច្ចជាតិ និងអន្តរជាតិមានការអភិវឌ្ឍយ៉ាងពិតប្រាកដ។

# អនុសាសន៍

# អនុសាសន៍

ដើម្បីអោយការចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិអាចដំណើរការទៅបានយ៉ាងរលូន និងទទួលបាននូវសមិទ្ធិផលខ្ពស់ យើងខ្ញុំសូមផ្តល់នូវអនុសាសន៍ដល់ស្ថាប័នដែលទទួលបន្ទុកនៅលើវិស័យកម្មសិទ្ធបញ្ញាទាំងអស់នេះគួរតែអនុវត្តនូវកិច្ចមួយចំនួនដូចជាៈ

យកចិត្តទុកដាក់ក្នុងការពង្រឹង ទៅលើការបណ្តុះបណ្តាលធនធានមនុស្ស ជាពិសេសគឺអ្នកជំនាញការចុះបញ្ជីអោយយល់បានច្បាស់ពីប្រកាសនីយបត្រតក្កកម្ម។

ពង្រឹងច្បាប់នៃប្រកាសនីយបត្រតក្កកម្ម ដើម្បីការពារទៅដល់រាល់តក្កករ ជៀសវាងការរំលោភបំពានទៅដល់សិទ្ធម្ចាស់ប្រកាសនីយបត្រតក្កកម្ម។

បន្តការធ្វើកិច្ចសហប្រតិបត្តិការជាសកលដើម្បីអោយមានភាពរឹងមាំ ក្នុងគោលបំណងចង់អោយវិស័យនៃប្រកាសនីយបត្រតក្កកម្មមានការផ្លាស់ប្តូរ ឬការស្នើសុំជំនួយបច្ចេកទេសផ្សេងៗ។

ធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយ អំពីប្រកាសនីយបត្រតក្កកម្មទៅកាន់ប្រជាពលរដ្ឋនៅក្នុងប្រទេស។

សរុបមក ដើម្បីអោយការអនុវត្តនេះមានភាពរីកចម្រើន និងការអភិវឌ្ឍន៍ទាំងជាតិ និងអន្តរជាតិ ស្ថាប័នទាក់ទងទាំងអស់គួរតប្បីខិតខំប្រឹងប្រែងសម្រេចផែនការទាំងនេះ ទើបធ្វើអោយប្រទេសជាតិក្លាយជាតំបន់មួយដែលមានការអភិវឌ្ឍផងដែរ។

# ឯកសារយោង

# ឯកសារយោង

- **សន្ធិសញ្ញាអន្តរជាតិ**
  - សន្ធិសញ្ញាសហប្រតិបត្តិការ ស្ដីពីប្រកាសនីយបត្រតក្កកម្ម។
  - អនុសញ្ញាទីក្រុងប៉ារីស, ស្ដីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម, ២០.មីនា.១៨៨៣ ធ្វើការកែប្រែចុងក្រោយនៅទីក្រុង ស្តុកហូម ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧ ហើយបានធ្វើវោសោធនកម្ម ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៩។ ។
  - កិច្ចព្រមព្រៀងស្ដីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធបញ្ញា (កិច្ចព្រមព្រៀង TRIPS ឆ្នាំ ១៩៩៤)។
  - វិធានស្ថិតក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ។
- **បទដ្ឋានគតិយុត្តជាតិ**
  - ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម, ប្រកាសឲ្យប្រើថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០២។
  - ច្បាប់ស្តីពី វិសោធនកម្មមាត្រា ៣៧ មាត្រា ៣៨ មាត្រា ១០៩ និងមាត្រា ១៣៦ នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម, ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០០៣។
  - ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពី ការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧។
- **ប្រកាស**
  - ប្រកាសស្តីពី ការគ្រប់គ្រង និងនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍, រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០១៩។

    https://wipolex-res.wipo.int/edocs/lexdocs/laws/km/kh/kh043km.pdf
  - ប្រកាសស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការទាក់ទងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក, រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០២១។

    https://www.misti.gov.kh/public/file/202203241648102663.pdf

## ➢ អនុស្សរណៈ


- អនុស្សរណៈយោគយល់គ្នាស្តីពី ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅព្រះរាជាណាចក្រកម្ពុជា,

https://www.abacusip.com/_files/ugd/3e39e9_0ec339fe1c644efeb04c41fa81298b44.pdf?index=true


## ➢ សៀវភៅច្បាប់ទូទៅ


- លោក "កាន់ សុទ្ធប៉ូលីន", "នីតិកម្មសិទ្ធិបញ្ញា",(សិទ្ធិអ្នកនិពន្ធ ម៉ាក ប្រកាសនីយបត្រតក្កកម្ម), ឆ្នាំ២០១៤។
- លោក "ឃឹម គីរី", "នីតិកម្មសិទ្ធិបញ្ញាកម្ពុជា", ខែកញ្ញា ឆ្នាំ២០២២។
- លោក ឃឹម ឧត្តម, "នីតិកម្មសិទ្ធិបញ្ញា"។
- បណ្ឌិត "ទេពសុខ", "នីតិកម្មសិទ្ធិបញ្ញា", ឆ្នាំ២០២២-២០២៣។
- លោក "លឹម យូសួ", "នីតិកម្មសិទ្ធិបញ្ញា"។


## ➢ ប្រព័ន្ធអ៊ីនធឺណែត


- Abacus IP, CAMBODIA,"ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា", ខែកក្កដា ឆ្នាំ ២០១៥។

  https://vannarachincom.files.wordpress.com/2015/11/e19e98e19e82e19f92e19e82e19e91e19f81e19e9fe19e80e19f8de19ea2e19f86e19e96e19eb8e19e85e19f92e19e94e19eb6e19e94e19f8be19e94e19f92e19e9a.pdf
- តើអ្វីទៅជាប្រកាសនីយបត្រតក្កកម្ម, "នាយកដ្ឋានកម្មសិទ្ធបញ្ញា"

  Department of Intellectual Property Rights (cambodiaip.gov.kh)
- WIPO, "intellectual Property a power tool for Economic Growth"

  https://www.wipo.int/portal/en/index.html

# ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖ លិខិតូបករណ៍នៃការចូលជាសមាជិកសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២ សរ.ក/ប្រ

## លិខិតូបករណ៍នៃការចូលជាសមាជិក
## សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT)

តាមរយៈលិខិតូបករណ៍នេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមប្រកាសថា ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលត្រូវបានបង្កើតឡើង នៅរដ្ឋធានីវ៉ាស៊ីនតោន កាលពីថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ១៩៧០ និងត្រូវបានធ្វើវិសោធនកម្ម នៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៧៩ និងត្រូវបានកែសម្រួល នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៨៤ និងនៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០១។

អនុលោមតាមមាត្រា ៦៤(៥) នៃសន្ធិសញ្ញានេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមប្រកាសថា ព្រះរាជាណាចក្រកម្ពុជា មិនត្រូវបានចងដោយមាត្រា ៥៩ នៃសន្ធិសញ្ញានេះឡើយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦

ហត្ថលេខា

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# ឧបសម្ព័ន្ធទី២៖ ប្រកាសស្តីពីប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការទាក់ទង ពាក្យស្នើសុំ  ប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា  ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្ម និង ពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខ: ០៧៩ MISTI / ២០២១

# ប្រកាស
## ស្តីពី
## ការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការ ទាក់ទងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា ជាមួយអង្គភាព ប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៦ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្របក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.**_

ប្រកាសនេះ កំណត់ពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសប្រតិបត្តិការពន្លឿនការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ដែលទាក់ទងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាព


ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

ប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក ដោយអនុលោមតាមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែល មានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

## ផ្នែកទី២
## ការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម

**ប្រការ២.** _

ការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ដែលទាក់ទងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក ត្រូវធ្វើនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៣.** _

អ្នកដាក់ពាក្យសុំអាចស្នើសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម បានចំពោះតែពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលដាក់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយប្រើប្រាស់លទ្ធផលស្រាវជ្រាវ និងពិនិត្យតក្កកម្ម ដែលបានធ្វើដោយអង្គភាពប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក។

**ប្រការ៤.** _

ការស្នើសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម អាចត្រូវបានទទួលចំពោះតែពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលបានដាក់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ត្រូវមានការប្រកាសសិទ្ធិអាទិភាព ក្រោមអនុសញ្ញាក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ផ្អែកលើមូលដ្ឋានពាក្យសុំប្រកាសនីយបត្រតក្កកម្មសហរដ្ឋអាមេរិក ឬ

២-ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលបម្រើជាមូលដ្ឋានសម្រាប់ ប្រកាសសិទ្ធិអាទិភាព ក្រោមអនុសញ្ញាក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ដោយផ្អែកលើមូលដ្ឋានពាក្យសុំប្រកាសនីយបត្រតក្កកម្មសហរដ្ឋអាមេរិក រួមទាំងពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលស្ថិតក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលចូល ក្នុងដំណាក់កាលជាតិ ឬ

៣-ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ដែលមានមូលដ្ឋានដូចគ្នាទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មសម្រាប់ប្រកាសសិទ្ធិអាទិភាព ក្រោមអនុសញ្ញាទីក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ដោយផ្អែកលើមូលដ្ឋានពាក្យសុំអង្គភាពប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក រួមទាំងពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលស្ថិតក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលចូលក្នុងដំណាក់កាលជាតិ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ៥.**

ក្នុងការស្នើសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យសុំត្រូវប្រើទម្រង់ពាក្យសុំដូចបានភ្ជាប់ក្នុងឧបសម្ព័ន្ធ១ និងត្រូវបំពេញទិន្នន័យដូចខាងក្រោម៖

ក- ចំណងជើងតក្កកម្ម

ខ- កាលបរិច្ឆេទដាក់ពាក្យស្នើសុំ

គ- លេខសំណុំលិខិតស្នើសុំ

ឃ-ឈ្មោះអ្នកដាក់ពាក្យសុំ

ង-សំណុំលិខិតស្នើសុំទាក់ទងនឹងអង្គភាពប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក

ច-ឯកសារភ្ជាប់មួយចំនួនទៀតដែលត្រូវផ្តល់ដូចខាងក្រោម ៖

- ច្បាប់ចម្លងនៃពាក្យសុំប្រកាសនីយបត្រតក្កកម្មសហរដ្ឋអាមេរិក ដែលបានបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រ ប្រកាសនីយបត្រតក្កកម្ម និងមានការបញ្ជាក់ដោយអង្គភាពប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក។
- បកប្រែជាភាសាខ្មែរនូវសេចក្តីអះអាង និងលក្ខខណ្ឌបច្ចេកទេស ដែលពិពណ៌នានៅក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្ម។ អ្នកដាក់ពាក្យសុំត្រូវផ្តល់សេចក្តីបកប្រែក្នុងរយៈពេលប្រាំមួយ (៦)ខែ ចាប់ពីកាលបរិច្ឆេទនៃការស្នើសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម។
- តារាងអំពីការផ្លាស់ប្តូរសេចក្តីអះអាង។

**ប្រការ៦.**

ការស្នើសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម អាចទទួលយកបានចំពោះតែប្រកាសនីយបត្រតក្កកម្មដែលបានដាក់នៅអង្គភាពប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក ហើយមានលក្ខខណ្ឌដូចខាងក្រោម ៖

១-ត្រូវតែជាពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មសហរដ្ឋអាមេរិក ដែលមានការបរិច្ឆេទដំបូងបង្អស់ដូចគ្នានឹង ពាក្យស្នើសុំដែលបានដាក់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ។

២-ត្រូវតែមានទំនាក់ទំនងជាមួយពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក។

៣-ត្រូវតែមានសេចក្តីអះអាង ក្នុងពាក្យស្នើសុំដែលបានដាក់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ហើយមានសេចក្តីអះអាងមួយ ឬច្រើនដូចទៅនឹងសេចក្តីអះអាង ដែលមាននៅក្នុងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មសហរដ្ឋអាមេរិក ដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្ម ដោយអង្គភាពប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក។

**ប្រការ៧.**

ការស្នើសុំពន្លឿនលើការផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការពន្លឿនការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក ពុំមានការបង់កម្រៃសេវាឡើយ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៧៨៥
អ៊ីម៉ែល: misti.smcabinet@gmail.com

## ផ្នែកទី៣
## អវសានប្បញ្ញត្តិ

**ប្រការ៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ប្រធាននាយកដ្ឋាននីតិកម្ម គ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាដូចតទៅ។

ថ្ងៃ ចន្ទ ១រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

**កន្លែងទទួល៖**
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៤
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mistcabinet@gmail.com

# ឧបសម្ព័ន្ធទី៣៖ ពាក្យសុំប្រកាសនីយបត្រតក្កកម្មកម្ពុជា

ឧបសម្ព័ន ១ (ពប្រក)
ANNEX 1 ( AGPC )

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry Science Technology and Innovation
អគ្គនាយកដ្ឋានឧស្សាហកម្ម
General Department of Industry
នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
Department of Industrial Property

## ពាក្យសុំប្រកាសនីយបត្រតក្កកម្មកម្ពុជា
## Request Form

<table>
<tr><td rowspan="4">**កម្មវត្ថុ៖ សំណើសុំពន្លឿនលើការផ្តល់ប្រកាសនីយបត្រតក្កកម្មសហរដ្ឋអាមេរិកនៅកម្ពុជា**<br>Subject: Request for an accelerated decision under the AGPC</td><td>**សម្រាប់មន្ត្រីកាន់កាប់បញ្ជី**<br>For Registrar</td></tr>
<tr><td>**កាលបរិច្ឆេទទទួល** :<br>Receiving Date</td></tr>
<tr><td>**លេខរបស់សំណុំលិខិតស្នើសុំ** :<br>Application Number</td></tr>
<tr><td>**កាលបរិច្ឆេទសុំចុះបញ្ជី** :<br>Filing Date</td></tr>
</table>

លេខសំណុំសំណុំលិខិតស្នើសុំ / Patent Application number: ..................................................

ការបរិច្ឆេទសុំចុះបញ្ជី / Date of filing :..................................................

ចំណងជើងនៃតក្កកម្ម / Title of invention :..................................................

..........................................................................................................................................

អ្នកដាក់ពាក្យសុំ / Applicant :..................................................

ពាក្យស្នើសុំពន្លឿនលើការផ្តល់ប្រកាសនីយបត្រតក្កម្មសហរដ្ឋអាមេរិកលេខ / Corresponding patent application number :..................................................

ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម / Attached Documents:

□ ច្បាប់ចម្លងនៃពាក្យសុំប្រកាសនីយបត្រតក្កកម្មសហរដ្ឋអាមេរិក ដែលបានបោះពុម្ពផ្សាយក្នុងព្រឹត្តបត្រប្រកាសនីយបត្រតក្កកម្ម និងមានការបញ្ជាក់ដោយអង្គភាពប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជសញ្ញាសហរដ្ឋអាមេរិក។

□ A copy of patent gazette in the corresponding USPTO patent application, and

its certification by the USPTO

□ បកប្រែជាភាសាខ្មែរនូវសេចក្តីអះអាង និងលក្ខណបច្ចេកទេស ដែលពិពណ៌នានៅក្នុងព្រឹត្តបត្រប្រកាសនីយបត្រតក្កកម្ម។

□ Translation of Claims and Specification described in the patent gazette in Khmer ( Translator must provide a self – declaration)

( ចំណាំ )អ្នកដាក់ពាក្យសុំត្រូវផ្តល់សេចក្តីបកប្រែក្នុងរយៈពេលប្រាំមួយខែ( ៦ )ចាប់ពីកាលបរិច្ឆេទនៃការស្នើសុំពន្លឿនលើការផ្តល់ប្រកាសនីយបត្រតក្កកម្ម( AGPC)។

( Note ) Applicant may submit the translation within six months of date on which the request of the AGPC was filed.

□ តារាងអំពីការផ្លាស់ប្តូរសេចក្តីអះអាង / Claims correspondence table

ហត្ថលេខា/ Signature